ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

FUTABA MICROFINANCE PLC.




# របាយការណ៍ប្រចាំឆ្នាំ

# ២០២៣

# ផែនទីតំបន់ប្រតិបត្តិការ




១

**កាវិយាល័យកណ្តាល និងសាខាការិយាល័យកណ្តាល**

- អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- (៨៥៥) ២៣ ២២៤ ៣៣៣ / (៨៥៥) ៧០ ៣១២ ៣៣៣

២

**សាខាខណ្ឌពោធិ៍សែនជ័យ**

- ផ្ទះលេខ៧៨ក ផ្លូវជាតិលេខ៤ ភូមិព្រៃស្វាយ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- (៨៥៥) ៧០ ៣១៦ ៣៣៣

៣

**សាខាខណ្ឌព្រែកព្នៅ**

- #18A-B ផ្លូវលេខ៥ ភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- (៨៥៥) ៧០ ៣១៧ ៣៣៣

៤

**សាខាក្រុងច្បារមន**

- ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា។
- (៨៥៥) ៧០ ៣១៤ ៣៣៣

៥

**សាខាក្រុងដូនកែវ**

- ភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជា។
- (៨៥៥) ៧០ ៩៦៤ ៣៣៣

# សាខាក្រុងដូនកែវ




ស្កេនក្រង់នេះដើម្បីស្វែងរកទីតាំងសាខា




សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងលេខដូចខាងក្រោម៖

**070 964 333 / 070 312 333**

# ចំណាប់អារម្មណ៍របស់លោកប្រធានក្រុមប្រឹក្សាភិបាល




ក្នុងស្ថានភាពពេលនេះយើងអាចមើលឃើញថា សេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៣ មានកំណើនតិចជាង ការរំពឹងទុកពីឆ្នាំមុន បន្ទាប់ពីបានឆ្លងកាត់ឧបសគ្គជាបន្តបន្ទាប់នៃវិបត្តិមេរោគកូវីដ ការបន្តដំឡើងការប្រាក់ គោលដើម្បីកាត់បន្ថយអតិផរណា ការរួមតូចនៃលំហនយោបាយសារពើពន្ធ ការកើនឡើងហានិភ័យនៃការ បែងចែកភូមិសាស្ត្រនយោបាយ វិបត្តិអចលនទ្រព្យ និងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុក ដែលបានដាក់ បន្ទុកដល់ពាណិជ្ជកម្ម ការប្រើប្រាស់ និងការវិនិយោគជាសកល។ តាមរយៈការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០២៣ អាចសម្រេចបានក្នុងអត្រា ៣% ដែលក្នុងនោះប្រទេសកំពុងអភិវឌ្ឍន៍កើនក្នុងអត្រា ១,៥% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើន ក្នុងអត្រា ៤% និងសេដ្ឋកិច្ចតំបន់អាស៊ានកើនក្នុងអត្រា ៤,៤%។ ហើយតាមរបាយការណ៍ប្រចាំឆ្នាំ២០២៣ ដោយធនាគារជាតិនៃកម្ពុជា បានបង្ហាញថា វិបត្តិសេដ្ឋកិច្ចពិភពលោកបានដាក់សម្ពាធដល់សេដ្ឋកិច្ចរបស់ កម្ពុជាផងដែរ ជាពិសេសការនាំចេញផលិតផលកាត់ដេរ និងកំណើនវិស័យសំណង់ និងអចលនទ្រព្យ។ ប៉ុន្តែការងើបឡើងវិញនៃវិស័យទេសចរណ៍ កំណើនការនាំចេញផលិតផលមិនមែនកាត់ដេរ និងកំណើនតម្រូវការក្នុងស្រុកបានរួមចំណែកគាំទ្រដល់សេដ្ឋកិច្ចកម្ពុជាឱ្យមានការកើនឡើងក្នុងអត្រា ៥,៥% នៅឆ្នាំ២០២៣ ខ្ពស់ជាងឆ្នាំ២០២២ (មាន ៥,៣%) បន្តិច ដែលការរំពឹងទុកនេះនឹងមានការកើនឡើងនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់តាមរយៈការលើកឡើងរបស់ធនាគារពិភពលោកនៅពាក់កណ្តាលឆ្នាំ២០២៣ នេះ។ ការសម្រេចបានកំណើននេះ កើតឡើងដោយសារមានការគាំទ្រមិនអាចខ្វះបាននូវស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះនៃជំនឿ ទុកចិត្ត និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលរាជរដ្ឋាភិបាលអាណត្តិថ្មី បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទី១ ដែលមានគោលដៅច្បាស់លាស់ និងទស្សនៈវិស័យវែងឆ្ងាយក្នុងការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គម ដោយផ្តោតលើចំណុចអាទិភាពគន្លឹះទាំង ៥ គឺមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

ចំពោះទំនុកចិត្តមកលើប្រព័ន្ធធនាគារ និងមីក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជានូវបន្តមានភាពរឹងមាំ ទោះបី ឆ្នាំ២០២៣ ជាឆ្នាំបោះឆ្នោត ហើយប្រព័ន្ធធនាគារនៅក្នុងប្រទេសមួយចំនួនបានរងការប៉ះទង្គិចដោយ ការដួលរលំនៃធនាគារពាណិជ្ជក៏ដោយ។ ហើយនៅក្នុងតំបន់ឬប្រទេសនីមួយៗអាចមានការកើនឡើងបំណុល និងហានិភ័យឥណទានកើតឡើងលើវិស័យអចលនទ្រព្យ។ ការថយចុះកំណើនឥណទានគួបផ្សំ នឹងការបញ្ចប់នៃការរៀបចំឥណទាន រៀបចំឡើងវិញក្នុងអំឡុងពេលវិបត្តិកូវីដ បានបណ្តាលឱ្យអនុបាតឥណទានមិនដំណើរការកើនឡើង ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបន្តបង្កើនការត្រួតពិនិត្យ តាមដាន វាយតម្លៃ និងធ្វើស្ថិតិជាប្រចាំលើហានិភ័យដែលអាចកើតមានឡើង។ គិតត្រឹមដំណាច់ឆ្នាំ២០២៣ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង ៨,៦% ដល់ ៣៤៦,៧ ទ្រីលានរៀល (ស្មើនឹង ៨៤,៣ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះវិស័យធនាគារមានសមាមាត្រ ៩១,៨%

វិស័យមីក្រូ ហិរញ្ញវត្ថុ ៧,៦% និងវិស័យភតិសន្យាហិរញ្ញវត្ថុ ០,៦% ជាមួយចំនួនគណនីប្រាក់បញ្ញើអតិថិជនដល់ ១៨,៩ លានគណនី និងគណនីឥណទានអតិថិជនដល់ ៣,៩ លានគណនី។ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ធនាគារជាតិនៃកម្ពុជាបានបង្ហាញថា ធនាគារពាណិជ្ជមានចំនួន ៥៨ ធនាគារឯកទេសមានចំនួន ០៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ០៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៨៣ គ្រឹះស្ថានឥណទានជនបទមានចំនួន ១១៤ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមានចំនួន ១៦ អ្នកដំណើរការតតិយភាគីមានចំនួន ០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់មានចំនួន ៣៣ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជាមានចំនួន ០១ ការិយាល័យតំណាងធនាគារបរទេសមានចំនួន ០៥ និងអាជីវករប្តូរប្រាក់មានចំនួន ២.៩១៥។ ចំណុចនេះយើងអាចមើលឃើញថា ទោះបីជាទទួលរងឥទ្ធិពលពីវិបត្តិ ក៏ប្រព័ន្ធធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅតែបន្តមានស្ថិរភាពរឹងមាំ និងភាពធន់ ដោយមានការបន្តបណ្តាក់ទុនបន្ថែមពីអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកមកលើវិស័យនេះនៅកម្ពុជា។ ក្នុងនោះវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានៅតែបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ការចូលរួមថែរក្សាបរិស្ថាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង និងសង្គម ជាពិសេសការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ។

ទោះបីមានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ និងបញ្ហាអូសបន្លាយនៃសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែនកន្លងមក ដែលបានជះឥទ្ធិពលមួយចំនួនដល់វិស័យធនាគារ និងហិរញ្ញវត្ថុ ក៏គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានខិតខំប្រឹងប្រែងបង្កើតសាខាថ្មីមួយបន្ថែមទៀត គឺសាខាក្រុងដូនកែវ ខេត្តតាកែវ ដែលបានទទួលការអនុញ្ញាត និងផ្តល់អាជ្ញាបណ្ណពីធនាគារជាតិ នៃកម្ពុជាកាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ ទៅតាមផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ហើយនាចុងឆ្នាំ២០២៣ នេះ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក៏បានផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ខ្លួនផងដែរក្នុងកម្រិតគណៈគ្រប់គ្រង ដោយបានតែងតាំងនាយកប្រតិបត្តិថ្មីដែលជាជនជាតិខ្មែរ ដើម្បីបន្តការដឹកនាំ គ្រប់គ្រង និងអនុវត្តការងារឱ្យ កាន់តែមានប្រសិទ្ធភាព។ ទោះជាស្ថិតនៅស្ថានភាពលំបាកនេះក៏ដោយ នៅក្នុងឆ្នាំ២០២៣ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែអាចរក្សាប្រាក់ចំណេញរបស់ខ្លួនបានចំនួន ២៦០.៤៦៤ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៥៨០.៨៦២ ដុល្លារអាមេរិក។ លទ្ធផលនេះបង្ហាញពីការចូលរួម សហការពីគណៈគ្រប់គ្រង បុគ្គលិកទាំងអស់ និងពិសេសផ្នែកឥណទានផ្ទាល់ ដែលបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងដោះស្រាយបំណុលយឺតយ៉ាវឱ្យបានទាន់ពេលវេលា។

ក្នុងនាមប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជន និងភាគទុនិកជប៉ុនរបស់យើងខ្ញុំ នៅតែមានសុច្ឆន្ទៈក្នុងការប្រើប្រាស់សេវា និងផលិតផលរបស់គ្រឹះស្ថាន ដើម្បីចូលរួមចំណែក អភិវឌ្ឍអាជីវកម្ម និងធនធានមនុស្សជំនាន់ក្រោយនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងនាយកប្រតិបត្តិ នាយករងប្រតិបត្តិ និងបុគ្គលិកទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រាប់ការគាំទ្រ និងការខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន និងការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះធនាគារជាតិនៃកម្ពុជា និងដៃគូសហប្រតិបត្តិការ ដែលតែងតែផ្តល់ការសហការ ការគាំទ្រ និងអនុសាសន៍នានាដល់គ្រឹះស្ថានយើងខ្ញុំ ដើម្បីចាត់ចែងនូវរាល់សកម្មភាពការងារទាំងអស់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពរហូតមកដល់ពេលបច្ចុប្បន្ន និង នាពេលអនាគតផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ វិបុលសុខ ចូលកើតមានដល់លោកអ្នក និងក្រុមគ្រួសារ នូវសេចក្តីចម្រើនមានបាន ជោគជ័យគ្រប់ភារកិច្ចការងារ ជានិច្ចនិរន្តតរៀងទៅ។

លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល

# ចំណាប់អារម្មណ៍របស់លោកនាយកប្រតិបត្តិ




ជូនចំពោះអតិថិជន និងដៃគូពាណិជ្ជកម្មជាទីគោរព!

សូមជម្រាបជូនថា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានទទួលអាជ្ញាបណ្ណជាស្ថាប័នហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបសកម្មភាពអាជីវកម្ម នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រងព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគត របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍សម្រាប់ប្រកបអាជីវកម្មជាផ្លូវការមកឱ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ជំនួសឱ្យអាជ្ញាបណ្ណដែលមានកំណត់រយៈពេល ៣ឆ្នាំ។ ហើយក្នុងអំឡុង ឆ្នាំ២០២៣ នេះ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានខិតខំប្រឹងប្រែងបង្កើតសាខាថ្មីមួយ បន្ថែមទៀត គឺសាខាក្រុងដូនកែវ ខេត្តតាកែវ ដែលបានទទួលអាជ្ញាបណ្ណស្របច្បាប់ពីធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣។

ស្ថានភាពសេដ្ឋកិច្ចពិភពលោក ក្នុងតំបន់ និងសេដ្ឋកិច្ចប្រទេសកម្ពុជា មិនទាន់មានភាពល្អប្រសើរនៅឡើយទេ ហើយបើក្រឡេកមកមើលស្ថានភាពនៃវិស័យធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថាន បង់រំលស់ ក៏ដូចជាគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅក្នុងឆ្នាំ២០២៣ មកនេះក៏ជួបប្រទះបញ្ហាប្រឈមមួយចំនួនផងដែរជាពិសេសទៅលើការគ្រប់គ្រងគុណភាពឥណទាន ដែលបំណុលយឺតយ៉ាវមានការ កើនឡើងច្រើន ដោយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ គ្រឹះស្ថានបានបើកប្រតិបត្តិការមករយៈពេលជិត ៨ឆ្នាំទៅ ហើយដែលមានបុគ្គលិកសរុបចំនួន ៩២ នាក់ ស្ត្រីចំនួន ២៨ នាក់ និងបុរសចំនួន ៦៤ នាក់ ដែលកំពុងបម្រើការងារនៅការិយាល័យកណ្តាល និងសាខាចំនួន ០៥ការិយាល័យសាខារួមមានទីស្នាក់ការ កណ្តាល (រួមជាមួយសាខាការិយាល័យកណ្តាល) សាខាខណ្ឌព្រែកព្នៅ សាខាខណ្ឌពោធិ៍សែនជ័យ សាខាក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) និងសាខាក្រុងដូនកែវ (ខេត្តតាកែវ) ជាមួយនឹងអតិថិជនដែលបាន នឹងកំពុងប្រើប្រាស់កម្ចីមានសរុប ៨៨៣នាក់ ស្មើនឹងផលបត្រឥណទានសរុប ១៤.៣៨៣.០៧៦ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងរបស់មន្ត្រីឥណទានចំនួន ២៦ នាក់។ ផលប៉ះពាល់នេះបានធ្វើឱ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានអត្រាហានិភ័យផលបត្រឥណទានមានការកើនឡើងខ្ពស់ដល់អត្រា ១៥,៩៦% ហើយអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា ០,០៦% ប៉ុន្តែ បើទោះជាស្ថិតក្នុងស្ថានភាពនេះក៏ដោយ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែអាចរក្សាប្រាក់ចំណេញរបស់ខ្លួននៅបំណាច់ឆ្នាំ២០២៣ ចំនួន ២៦០.៤៦៤ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៥៨០.៨៦២ ដុល្លារអាមេរិក។

ទោះបីគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មិនទាន់មានការិយាល័យប្រតិបត្តិការឱ្យបានទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា

ក៏ចក្ខុវិស័យរបស់យើងខ្ញុំ ត្រូវតែខិតខំអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងពេលបច្ចុប្បន្ន ក៏ដូចពេលអនាគតតាមរយៈការធ្វើឱ្យមានលំនឹងស្ថិរភាព តម្លាភាពលើផ្នែកទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា និងផែនការយុទ្ធសាស្ត្ររយៈពេលវែងដែលនឹងពង្រីកតំបន់ប្រតិបត្តិការឱ្យបានទូលំទូលាយបន្ថែមទៀតនៅតាមបណ្តាខេត្តផ្សេងៗទៀត ដែលជាបំណងប្រាថ្នាដ៏សុចរិត ក៏ដូចជាគោលដៅរបស់គ្រឹះស្ថានយើងខ្ញុំផងដែរ។

គ្រឹះស្ថានរបស់យើងខ្ញុំ នឹងរិះរកវិធីក្នុងការផ្តល់ជូននូវសេវាដ៏សម្បូរបែប និងប្រកបដោយភាពច្នៃប្រឌិតខ្ពស់ លើដំណោះស្រាយហិរញ្ញវត្ថុថ្មីៗ ជូនចំពោះអតិថិជនចាស់ និងថ្មីទាំងអស់។ កន្លងមកដើម្បីបំពេញតម្រូវការ របស់អតិថិជន គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតផលិតផលសេវាហិរញ្ញវត្ថុជាច្រើនដែលរួមមាន ឥណទានអាជីវកម្ម ឥណទានកសិកម្ម ឥណទានគេហដ្ឋាន ឥណទានសម្រាប់ប្រើប្រាស់ ឥណទានបុគ្គលិក ឥណទានសម្រាប់ការសិក្សា និងឥណទាននិយោជិត។ ចំពោះឥណទានបុគ្គលិក និងឥណទានសម្រាប់ការសិក្សា ត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់ទាបបំផុត ជាមួយនឹងសេវាល្អឥតខ្ចោះ ដែលមិនធ្លាប់មានក្នុងគោលដៅចូលរួមលើកស្ទួយផ្នែកសង្គម គាំទ្រជីវភាពគ្រួសាររបស់បុគ្គលិក និងអភិវឌ្ឍ នូវវិស័យធនធានមនុស្ស។

ទន្ទឹមនឹងការបំពេញតម្រូវការអតិថិជនក្នុងអំឡុងឆ្នាំ២០២៣ យើងក៏បានយកចិត្តទុកដាក់លើការពង្រឹងប្រព័ន្ធ នៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន បង្កើតសាខាថ្មីបន្ថែមនៅខេត្តតាកែវ និងការកែសម្រួលរចនាសម្ព័ន្ធកម្រិត គណៈគ្រប់គ្រងដើម្បីឱ្យការប្រតិបត្តិមានភាពរឹងមាំដោយផ្តោតលើការបណ្តុះបណ្តាលចំណេះជំនាញបុគ្គលិក និងបច្ចុប្បន្នភាពលើគោលការណ៍នីតិវិធីនានា ព្រមទាំងត្រូវប្រតិបត្តិតាមច្បាប់ ឬបទប្បញ្ញត្តិដែលតម្រូវដោយ ធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធ។

ស្ថានភាពសេដ្ឋកិច្ចពិភពលោកអាចនឹងធូរស្រាល និងប្រព័ន្ធធនាគារនិងមីក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជានូវ បន្តមានភាពរឹងមាំ ដែលបានធ្វើឱ្យសេដ្ឋកិច្ចក្នុងស្រុករបស់កម្ពុជានឹងវិលទៅរកភាពប្រក្រតីវិញនូវមុខរបរ និងអាជីវកម្មនានាមានដំណើរការល្អប្រសើរឡើងវិញនៅថ្ងៃខាងមុខឆាប់ៗ យើងសង្ឃឹម និងជឿជាក់ថា គ្រឹះស្ថានយើងខ្ញុំនឹងបន្តប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងក្លាយជាមាគ៌ាសម្រាប់អ្នកជំនាន់ក្រោយកម្ពុជា ដែលសម្រេចយកភាពត្រឹមត្រូវ ស្មើគ្នា និងរក្សាឱ្យបាននូវតម្លាភាព ជាមូលដ្ឋានក្នុងវិស័យសេវាហិរញ្ញវត្ថុ។ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានការគាំទ្រមូលនិធិពីភាគទុនិកឯកកម្មសិទ្ធិនៃប្រទេសជប៉ុន ដែលយើងខ្ញុំអាចចាត់ចែងប្រកបដោយភាពស្ទាត់ជំនាញ និងផ្តល់សេចក្តីសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការអតិថិជន។

ដើម្បីឱ្យ “សុបិនអតិថិជនក្លាយជាការពិត” យើងខ្ញុំរីករាយស្វាគមន៍សហការក្នុងការផ្តល់សេវាហិរញ្ញវត្ថុយ៉ាងកក់ក្តៅ និងជាទីទុកចិត្តបំផុតជូនអតិថិជនទាំងអស់ និងគ្រប់ពេលវេលាដែលត្រូវការ។

ជាទីបញ្ចប់ ក្នុងនាមគណៈគ្រប់គ្រងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជន ភាគទុនិកជប៉ុន ក្រុមប្រឹក្សាភិបាល នាយករងប្រតិបត្តិ និងបុគ្គលិកទាំងអស់ ដែលតែងតែគាំទ្រ និងការខិតខំប្រឹងប្រែងក្នុងការអនុវត្តការងារទៅតាមការទទួលខុសត្រូវ និងផែនការយុទ្ធសាស្ត្ររបស់ គ្រឹះស្ថានកន្លងមក ក៏ដូចជាធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការសហការ និងការគាំទ្រដល់គ្រឹះស្ថាន យើងខ្ញុំ។

សូមសុបិនរបស់លោកអ្នកក្លាយជាការពិត។



លោក អុំ ពិសិដ្ឋ
នាយកប្រតិបត្តិ

# មាតិកា




ស្កេនត្រង់នេះដើម្បីចូលឆានែលរបស់យើងខ្ញុំ

០១ ផែនទីតំបន់ប្រតិបត្តិការ
០២ សាខាក្រុងដូនកែវ
០៣ ចំណាប់អារម្មណ៍របស់លោកប្រធានក្រុមប្រឹក្សាភិបាល
០៥ ចំណាប់អារម្មណ៍របស់លោកនាយកប្រតិបត្តិ

## សមិទ្ធផលសំខាន់ៗ

១០ លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ
១២ សមិទ្ធផលប្រតិបត្តិការសំខាន់ៗ
១៣ លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

## អំពី ហ្វូតាបា

១៦ ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា
១៧ ប្រវត្តិសង្ខេបរបស់ ហ្វូតាបា
១៩ ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល
២០ ស្លាកសញ្ញារបស់ ហ្វូតាបា

## អភិបាលកិច្ច

២២ ម្ចាស់ភាគទុនិក និងដើមទុន
២៣ រចនាសម្ព័ន្ធ
២៤ ក្រុមប្រឹក្សាភិបាល
២៦ គណៈគ្រប់គ្រង

## សមិទ្ធផលអាជីវកម្ម

៣២ សមិទ្ធផលឥណទានតាមវិស័យ
៣៣ សមិទ្ធផលឥណទានតាមផលិតផល
៣៤ ចំណាត់ថ្នាក់ប្រភេទឥណទាន
៣៤ ចំណាត់ថ្នាក់ប្រភេទផលិតផល

## ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

៣៦ ការបណ្តុះបណ្តាលខាងក្នុង
៣៧ ការបណ្តុះបណ្តាលខាងក្រៅ
៣៧ សិក្ខាសាលាប្រចាំឆ្នាំ

## ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

៤០ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម
៤១ សវនកម្មផ្ទៃក្នុង

## របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មឯករាជ្យ

៤៤ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
៤៦ របាយការណ៍របស់សវនករឯករាជ្យ
៤៨ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
៤៩ របាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ
៥០ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
៥១ របាយការណ៍លំហូរសាច់ប្រាក់

## ដៃគូសហប្រតិបត្តិការរបស់ ហ្វូតាបា

៥៣ ដៃគូ
៥៣ ម្ចាស់កម្ចី

# សមិទ្ធផលសំខាន់ៗ

- លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ
- សមិទ្ធផលប្រតិបត្តិការសំខាន់ៗ
- លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

ស្កេនត្រង់នេះដើម្បីចូលរួម ឆានែលតេលេក្រាម



# លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ

| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដុល្លារអាមេរិក) | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | | | |
| សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅធនាគារ | ៨៤៥.១៩៣ | ២.១៧០.៥៥៧ | ១.៦៨៧.០៨៧ |
| សមតុល្យប្រាក់កម្ចីសរុប | ១៤.៣៨៣.០៧៦ | ១៣.២៩៥.៩២០ | ១៣.៣៨៧.៥៣៤ |
| ទ្រព្យសម្បត្តិ និងឧបករណ៍-សម្ភារៈសរុប | ១៧៩.១៩៧ | ៩៨.៣៨១ | ៨៤.០៦៤ |
| ទ្រព្យសម្បត្តិផ្សេងៗ | ១៧៣.៣៩៦ | ១៧៨.៩២២ | ១៧២.៤១១ |
| **សរុបទ្រព្យសកម្ម** | **១៥.៥៨០.៨៦២** | **១៥.៧៤៣.៧៨០** | **១៥.៣៣១.០៩៦** |
| បំណុល | | | |
| បំណុលផ្សេងៗ និងសំវិធានធន | ១.៧១២.៨៣៤ | ១.៦៣៦.២១៦ | ១.៦៦១.៨៤៧ |
| កម្ចីរយៈពេលវែង និងកម្ចីរយៈពេលខ្លី | ៤.៦៤៧.១៨២ | ៥.១៤៧.១៨២ | ៥.១៥៨.២៩៣ |
| **បំណុលសរុប** | **៦.៣៦០.០១៦** | **៦.៧៨៣.៣៩៨** | **៦.៨២០.១៤០** |
| មូលធនភាគទុនិក | | | |
| ដើមទុន | ៧.០០០.០០០ | ៧.០០០.០០០ | ៧.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៨២៤.៤១៣ | ៧៩៨.៧៤៩ | ៤៧៤.២៥២ |
| ប្រាក់ចំណេញរក្សាទុក | ១.៣៩៦.៤៣៣ | ១.១៦១.៦៣៣ | ១.០៣៦.៧០៤ |
| មូលធនសរុប | ៩.២២០.៨៤៦ | ៨.៩៦០.៣៨២ | ៨.៥១០.៩៥៦ |
| **សរុបបំណុល និងមូលធនភាគទុនិក** | **១៥.៥៨០.៨៦២** | **១៥.៧៤៣.៧៨០** | **១៥.៣៣១.០៩៦** |

| របាយការណ៍លទ្ធផលពេញលេញ (ដុល្លារអាមេរិក) | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ចំណូលការប្រាក់ និងថ្លៃសេវាផ្សេងៗ | ១.៨៨៤.០២៩ | ១.៩៥៤.០៣១ | ១.៧៦៣.៣៦៦ |
| ចំណាយប្រតិបត្តិការ | ១.៦២៣.៥៦៥ | ១.៥០៤.៦០៥ | ១.៣០៤.៦៩៤ |
| **ប្រាក់ចំណេញសុទ្ធ** | **២៦០.៤៦៤** | **៤៤៩.៤២៦** | **៤៥៨.៦៧២** |

| សូចនាករសំខាន់ៗ (ដុល្លារអាមេរិក) | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| អនុបាតសោធនភាព | ៦១% | ៥៩% | ៥៧% |
| ប្រាក់ចំណេញសុទ្ធ ធៀបមធ្យមភាគទ្រព្យសកម្ម (RoA) | ២% | ៣% | ៣% |
| ប្រាក់ចំណេញសុទ្ធ ធៀបមធ្យមភាគមូលធន (RoE) | ៣% | ៥% | ៥% |

## សរុបបំណុល និងមូលធនភាគទុនិក ២០២៣






# សមិទ្ធផលប្រតិបត្តិការសំខាន់ៗ

| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដុល្លារអាមេរិក) | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ចំនួនការិយាល័យសាខា | ៥ | ៤ | ៤ |
| ចំនួនខេត្តប្រតិបត្តិការ | ១០ | ១០ | ១០ |
| ចំនួនស្រុកប្រតិបត្តិការ | ៥០ | ៤៤ | ៣៦ |
| ចំនួនឃុំប្រតិបត្តិការ | ១៧៧ | ១៥៥ | ១៤៨ |
| ចំនួនភូមិប្រតិបត្តិការ | ៤៤៧ | ៣៧៨ | ៣៤៨ |
| ចំនួនបុគ្គលិកសរុប | ៩២ | ៩០ | ៨៣ |
| ចំនួនមន្ត្រីឥណទាន | ២៧ | ២៦ | ២១ |
| មន្ត្រីឥណទានធៀបនឹងបុគ្គលិកសរុប | ២៩% | ២៩% | ២៥% |
| ចំនួនអតិថិជនសកម្ម | ៨០៣ | ៧០៧ | ៦៧៨ |
| ចំនួនគណនីឥណទានសកម្ម | ៨៤៣ | ៧៨៩ | ៧៥១ |
| ចំនួនគណនីឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ | ៣៣ | ៣០ | ៣៦ |
| សំពៀតឥណទានសរុប (ដុល្លារអាមេរិក) | ១៤.៣៨៣.០៧៦ | ១៣.២៩៥.៩២០ | ១៣.៣៨៧.៥៣៤ |
| សំពៀតឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ (ដុល្លារអាមេរិក) | ៥៣២.៧០៧ | ៥១១.៣៨២ | ៦៣៧.៥០២ |
| សំពៀតឥណទានជាមធ្យមក្នុងបុគ្គលិកម្នាក់ (ដុល្លារអាមេរិក) | ១៥៦.៣៣៨ | ១៤៧.៧៣២ | ១៦១.២៩៦ |
| ទំហំឥណទានជាមធ្យម (ដុល្លារអាមេរិក) | ១៦.២៨៩ | ១៦.៨៥២ | ១៧.៨២៦ |
| ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | ១៥,៩៦% | ១២,៦២% | ៧,២៨% |
| អនុបាតឥណទានលុបចេញពីបញ្ជី (ដុល្លារអាមេរិក) | ៨,៥៥៥ | ៣,៧៧៦ | - |




អនុបាតឥណទានលុបចេញពីបញ្ជី (ដុល្លារអាមេរិក)
**៨.៥៥៥**

សំពៀតឥណទានសរុប (ដុល្លារអាមេរិក)
**១៤.៣៨៣.០៧៦**

ទំហំឥណទានជាមធ្យម (ដុល្លារអាមេរិក)
**១៦.២៨៩**

ហានិភ័យឥណទានធំជាង ៣០ថ្ងៃ (%)
**១៥.៩៦**

សំពៀតឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ (ដុល្លារអាមេរិក)
**៥៣២.៧០៧**

# លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជានាឆ្នាំ២០២៣នេះ បានបង្ហាញសញ្ញាធូរស្រាលបន្តិច បន្ទាប់ពីរងផលប៉ះពាល់នៃវិបត្តិសាកលនាពេលកន្លងមក និងបន្តមានកំណើនលូតលាស់ឡើងវិញជាបណ្តើរៗ។ កត្តានេះបានផ្តល់ក្តីសង្ឃឹមអំពីភាពជោគជ័យបន្ថែមដល់ប្រតិបត្តិករអាជីវកម្មនានានៅគ្រប់វិស័យ រួមទាំងវិស័យហិរញ្ញវត្ថុផងដែរ។ ថ្នាក់ដឹកនាំគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក៏បានចាប់យកឱកាសដ៏ល្អនេះ អនុវត្តនូវផែនការពង្រីកអាជីវកម្មរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង និងបានបង្កើតសាខាថ្មីមួយទៀតនៅខេត្តតាកែវ ដោយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣។

ផ្អែកតាមផែនការអាជីវកម្មរយៈពេលវែង ធនធានមនុស្សដែលមានសក្តានុពល នៅតែជាតម្រូវការចាំបាច់ចម្បងសម្រាប់ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងការដើតួនាទីសំខាន់ ដើម្បីសម្រេចឱ្យបាននូវភាពជោគជ័យទាំងស្រុង ស្របតាមក្តីសុបិនរបស់ភាគទុនិក។ ទន្ទឹមគ្នានេះ ថ្នាក់ដឹកនាំកំពូលរបស់ ហ្វូតាបា បានផ្តល់ការគាំទ្រ ជំរុញលើកទឹកចិត្តបុគ្គលិកឆ្នើម តាមរយៈការផ្តល់ប័ណ្ណសរសើរ និងការដំឡើងតួនាទីផងដែរ។ កត្តានេះបាននាំឱ្យ ហ្វូតាបា រក្សាបាននូវធនធានមនុស្សល្អៗបន្តបម្រើការងារប្រកបដោយភាពកក់ក្តៅ ព្រមទាំងអាចជ្រើសរើសបុគ្គលិកថ្មីៗបន្ថែមទៀតប្រកបដោយប្រសិទ្ធភាព ស្របតាមផែនការជាក់ស្តែងផងដែរ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ស្ថិតិបុគ្គលិករបស់ **ហ្វូតាបា** មានចំនួនសរុប ៩២រូប (បុរស ៦៤រូប និងស្ត្រី ២៨រូប) មានការកើនឡើងចំនួន ០២រូប ធៀបទៅនឹងឆ្នាំ២០២២។

ខាងក្រោមនេះគឺជាទិន្នន័យបុគ្គលិកសង្ខេបរបស់ **ហ្វូតាបា**៖







បម្រែបម្រួលបុគ្គលិកពេញមួយឆ្នាំ
(ឆ្នាំ ២០២៣)
៣២
៣០
៣៣%
បុគ្គលិកចូលថ្មី
បុគ្គលិកលាឈប់
គិតជា %


កំណើនបុគ្គលិកចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២៣
៨០
៧៤
៧៧
៨៣
៩០
៩២
២០១៨
២០១៩
២០២០
២០២១
២០២២
២០២៣

# អំពី ហ្វូតាបា

- ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា
- ប្រវត្តិសង្ខេបរបស់ ហ្វូតាបា
- ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល
- ស្លាកសញ្ញារបស់ ហ្វូតាបា

ស្កេនត្រង់នេះដើម្បីទទួលបានព័ត៌មានលម្អិត



# ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា

ចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននាចុងឆ្នាំ២០១៥ មក គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ពីធនាគារជាតិនៃកម្ពុជា ក្រោមបេសកកម្ម និងទស្សនៈវិស័យដ៏ច្បាស់លាស់របស់ខ្លួន ដែលចង់ក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជាផងដែរ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណជូនគ្រឹះស្ថានហ្វូតាបា រយៈពេល ៣ឆ្នាំបន្ថែមទៀត ក្រោយមកដោយមើលឃើញពីប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទាន និងបានកែសម្រួលលើចំណុចខ្វះខាតតាមអនុសាសន៍នៃការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន **ហ្វូតាបា**។ ចាប់តាំងពីឆ្នាំ២០១៦ ក្រុមហ៊ុន AZUMA & CO., LTD. (ជាក្រុមហ៊ុនជប៉ុន) ក៏បានក្លាយជាភាគទុនិកកាន់កាប់ភាគហ៊ុន ១00% របស់គ្រឹះស្ថាន **ហ្វូតាបា**។

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ យើងមានបុគ្គលិកសរុបចំនួន ៩២នាក់ ស្ត្រីចំនួន ២៨នាក់ និងបុរសចំនួន ៦៤នាក់ ដែលកំពុងបម្រើការងារនៅការិយាល័យកណ្តាល និងសាខាចំនួន ០៥ ខេត្ត-រាជធានីរួមមាន សាខាការិយាល័យកណ្តាល សាខាខណ្ឌព្រែកព្នៅ សាខាខណ្ឌពោធិ៍សែនជ័យ សាខាក្រុងច្បារមន និងសាខាក្រុងដូនកែវ ចំពោះអតិថិនជនដែលបាន និងកំពុងទទួលកម្ចីមានសរុប ៨៨៣នាក់ ជាមួយនឹងផលបត្រឥណទានសរុប ១៤.៣៨៣.០៧៦ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងមន្ត្រីឥណទានចំនួន ២៦នាក់ ដែលលទ្ធផលជារួមមានការកើនឡើងតិចតួចលើផលបត្រឥណទាន និងចំនួនអតិថិជនបើប្រៀបធៀបនឹងឆ្នាំមុន តែគ្រឹះស្ថាន **ហ្វូតាបា** នៅតែបន្តដំណើររបស់ខ្លួនប្រកបដោយវិជ្ជមានទៅថ្ងៃអនាគត។ ក្នុងអំឡុង ៤ឆ្នាំកន្លងមកពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ យើងបានរក្សាកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រា 0.៤៦% និងអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា 0% ដែលនេះជាលទ្ធផលមួយដ៏ល្អប្រសើរលើការគ្រប់គ្រងឥណទានដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ ដោយឡែកចាប់តាំងពីឆ្នាំ២០២០ មកដល់ពេលនេះ មានការកើនឡើងលើកម្រិតហានិភ័យនៃផលបត្រឥណទានជាបន្តបន្ទាប់ផងដែរ ដោយក្នុងឆ្នាំ២០២៣ មានកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រា ១៥,៩៦% ហើយអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា 0,0៦% ដោយសារតែមានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ បញ្ហាសង្គ្រាមរវាងប្រទេសអ៊ុយក្រែន នឹងរុស្ស៊ី បញ្ហាគ្រោះទឹកជំនន់ និងបញ្ហាសេដ្ឋកិច្ចពិភពលោក។ ក្នុងស្ថានភាពនេះផងដែរ គ្រឹះស្ថាន **ហ្វូតាបា** បាន និងកំពុងផ្តល់ឥណទានរៀបចំឡើង វិញចំពោះតែផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដប៉ុណ្ណោះជូនអតិថិជនក្នុងអត្រា 0.៣៤% បើធៀបនឹងចំនួនអតិថិជនសរុប និងអត្រា 0.៦២% បើធៀបនឹងចំនួនផលបត្រឥណទានសរុប។

ចំពោះស្ថានភាពរបាយការណ៍ហិរញ្ញវត្ថុវិញ យើងឃើញថា គ្រឹះស្ថាន **ហ្វូតាបា** បានចំណាយពេលវេលាជាង ១ឆ្នាំ ទើបទទួលបានការចំណេញសុទ្ធរបស់ខ្លួនចាប់តាំងពីឆ្នាំ២០១៧ រហូតមក ហើយទោះបីមានផលប៉ះពាល់ពីកត្តាជាច្រើនមកយ៉ាងណាក៏ដោយក៏ការចំណេញសុទ្ធនៅបំណាច់ឆ្នាំ២០២៣ នេះមានចំនួន ២៦០.៤៦៤ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៥៨០.៨៦២ ដុល្លារអាមេរិក ដែលចំនួននេះមានការធ្លាក់ចុះជាងឆ្នាំមុន (ឆ្នាំ២០២២) ជាលទ្ធផល ហិរញ្ញវត្ថុមួយមិនទាន់ល្អប្រសើរនៅឡើយក្នុងស្ថានភាពដែលលំបាកនេះ តែគ្រឹះស្ថាននៅតែបន្តប្រតិបត្តិការសកម្មភាពអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងការខិតខំប្រឹងប្រែងជំនះនូវឧបសគ្គទាំងឡាយជាពិសេសការទប់ស្កាត់ការកើនឡើងនូវឥណទានយឺតយ៉ាវ និងការដោះស្រាយឱ្យបានទាន់ពេលវេលា។

ជាផ្នែកមួយក្នុងការគាំទ្រដល់ការអភិវឌ្ឍលើការអប់រំ និងជីវភាពរបស់បុគ្គលិក គ្រឹះស្ថាន **ហ្វូតាបា** ក៏បានផ្តល់ឥណទាន ក្នុងអត្រាការប្រាក់ទាបបំផុតលើឥណទានសិក្សា និងឥណទានបុគ្គលិក ដែលជាគោលដៅចម្បងរបស់ក្រុមប្រឹក្សាភិបាល នឹងម្ចាស់ភាគទុនិក ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** នឹងបន្តអនុវត្តន៍ផែនការគោល ផែនការរំកិលប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់នៅលើទីតាំងប្រតិបត្តិការរបស់គ្រឹះស្ថានដែលមានស្រាប់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។

# ប្រវត្តិសង្ខេបរបស់គ្រឹះស្ថាន ហ្វូតាបា

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងក្តីសុបិនរបស់ភាគទុនិកតាមរយៈគំនិតផ្តួចផ្តើម ព្រមទាំងការប្តេជ្ញាចិត្តខ្ពស់ ភាគទុនិកបានជម្នះនូវរាល់ឧបសគ្គទាំងឡាយរហូតទទួលបានអាជ្ញាបណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា លេខ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

នៅដើមឆ្នាំ២០១៦ គ្រឹះស្ថានក៏ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មជាមួយនឹងដើមទុនដំបូង $១.០០០.០០០ ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនជាច្រើន ដែលបង្ហាញពីភាពជោគជ័យដ៏ត្រចះត្រចង់។ ជាមួយគ្នានេះផងដែរ ក្នុងឆ្នាំ២០១៦នេះ ក្រុមហ៊ុន AZUMA & CO., LTD. ក៏បានក្លាយជាភាគទុនិកថ្មីរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន ដែលមានគោលគំនិតស្របគ្នាក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍមនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នឹងបន្តអនុវត្តផែនការគោលរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងនៃក្តីសុបិនរបស់ភាគទុនិក។ ជាក់ស្តែងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតការិយាល័យសាខាថ្មីចំនួនបី (៣) បន្ថែមទៀតនៅចុងឆ្នាំ២០១៦ ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារទូលំទូលាយ និងឆ្លើយតបទៅតាមកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់។ សាខាបើកថ្មីទាំងបី (៣) នោះ ត្រូវបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រង ព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន **ហ្វូតាបា** កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់សុពលភាពអាជ្ញាបណ្ណរយៈពេល ៣ឆ្នាំ បន្ថែមទៀត ហើយក្រោយមកធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន ហ្វូតាបា កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។ ទោះបីក្នុងស្ថានភាពលំបាកដែលរងផលប៉ះពាល់នៃមេរោគកូវីដ និងបញ្ហាសង្គ្រាមរវាងប្រទេសអ៊ុយក្រែន និងរុស្ស៊ីកន្លងមកក្តី យើងឃើញថា ក្នុងឆ្នាំ២០២៣ នេះ គ្រឹះស្ថាន **ហ្វូតាបា** បានខិតខំប្រឹងប្រែងពង្រីកប្រតិបត្តិការសាខារបស់ខ្លួនមួយទៀតនៅក្នុងខេត្តតាកែវ (សាខាក្រុងដូនកែវ) ឱ្យស្របទៅតាមផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន។ ហើយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ គ្រឹះស្ថាន **ហ្វូតាបា** មានប្រតិបត្តិការអាជីវកម្មមានរយៈពេល ៨ឆ្នាំមកហើយ ដែលមានទីតាំងកំពុងបម្រើសេវាអតិថិជនចំនួន ០៥ ខេត្ត/រាជធានី រួមមាន ការិយាល័យកណ្តាល (សាខាការិយាល័យកណ្តាល) សាខាខណ្ឌព្រែកព្នៅ សាខាខណ្ឌពោធិ៍សែនជ័យ សាខាក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) និងសាខាក្រុងដូនកែវ (ខេត្តតាកែវ)។ ហើយនាចុងឆ្នាំ២០២៣ នេះគ្រឹះស្ថាន **ហ្វូតាបា** ក៏បានផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងកម្រិតគណៈគ្រប់គ្រងដោយបានផ្លាស់ប្តូរតួនាទីនាយកប្រតិបត្តិ និងកែសម្រួលពីតួនាទីជំនួយការនាយកប្រតិបត្តិ ទៅជានាយករងប្រតិបត្តិ។




## ការវិវឌ្ឍន៍នៃដើមទុន



# ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

## ទស្សនៈវិស័យ និងបេសកកម្ម

### ទស្សនៈវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជននាពេលបច្ចុប្បន្ន និង អ្នកជំនាន់ថ្មី។

### បេសកកម្ម

ផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្តបំផុត ទៅកាន់ សហគ្រាស ខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គល ដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គម ដើម្បីសម្រេចនូវគោលបំណង ឬ ក្តីសុបិនរបស់ពួកគាត់ជាមួយអនាគតដ៏ប្រសើរ។

## តម្លៃស្នូល

- ០១ សុចរិតភាព
- ០២ មនុស្សជាតិ
- ០៣ ការតម្រង់ទិស
- ០៤ ការប្រកួតប្រជែង
- ០៥ សេចក្តីក្លៀវក្លា

# ស្លាកសញ្ញារបស់ ហ្វូតាបា

## និមិត្តសញ្ញា និងអត្ថន័យ

និមិត្តសញ្ញាសម្គាល់នេះ គឺសំដៅលើត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចមួយ ដែលបែកពន្លកចេញពីស្រទាប់ដី។

ត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចនេះ អាចលូតលាស់ជាឈើដ៏ធំមួយដើមនាពេលអនាគត ដ៏ឆាប់រហ័ស គឺអាស្រ័យលើការខិតខំបីបាច់ថែទាំ និងដាក់ជីយ៉ាងល្អិតល្អន់របស់យើងទាំងអស់គ្នា។
ក្នុងន័យនេះ យើងខ្ញុំជាគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី ប្រៀបបានទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុដ៏តូចមួយដែលទើបតែចាប់ផ្ដើមប្រតិបត្តិការរបស់ខ្លួនលើវិស័យហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ហើយយើងខ្ញុំអាចអភិវឌ្ឍជាធនាគារឈានមុខមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគតខាងមុខ ដើម្បីផ្ដល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ ធានាឲ្យបាននូវស្ថិរភាព និងផ្ដល់អនាគតដ៏ត្រចះត្រចង់ បម្រើជូនសាធារណៈជនទាំងអស់របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី ឬ ក៏ធនាគារ ហ្វូតាបា ប្រៀបដូចជាត្រួយនៃពន្លកធញ្ញជាតិដ៏តូចរីកលូតលាស់ទៅជាដើមឈើដ៏ធំនាពេលអនាគតដ៏ខ្លីខាងមុខ។

គ្រឹះស្ថានយើងខ្ញុំអាចអភិវឌ្ឍឆាប់រហ័សប្រៀបដូចនឹងដើមឈើដ៏ធំ គឺអាស្រ័យលើបុគ្គលិកគ្រប់លំដាប់ថ្នាក់នីមួយៗនៃគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី មានកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ផងដែរ ហើយក៏ពឹងផ្អែកលើទំហំទុន ដែលគ្រឹះស្ថានទទួលបានពីភាគទុនិករបស់ខ្លួន ដើម្បីបម្រើសេចក្ដីត្រូវការរបស់អតិថិជនយើងខ្ញុំ។

## ពណ៌

ពណ៌បៃតងនៃត្រួយពន្លកគ្រាប់ធញ្ញជាតិ គឺសំដៅភាពយកចិត្តទុកដាក់លើបរិស្ថានភាព សុខុដុម រវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាននាពេលបច្ចុប្បន្ន និង តទៅអនាគតសម្រាប់ជំនាន់ក្រោយ។

## ពាក្យស្លោក

**សុបិនក្លាយជាការពិត**

# អភិបាលកិច្ច

- ម្ចាស់ភាគទុនិក និងដើមទុន
- រចនាសម្ព័ន្ធ
- ក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង

### ឥណទានសិក្សា

. ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
. ទំហំឥណទានរហូតដល់ : ២.000 ដុល្លារ
. រយៈពេលរហូតដល់ : ៥ ឆ្នាំ



# ម្ចាស់ភាគទុនិក និងដើមទុន




AZUMA & Co.,Ltd. ជាភាគទុនិកឯកកម្មសិទ្ធិកាន់កាប់លើភាគហ៊ុន ១00ភាគរយ របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី សូមសម្តែងនូវសុច្ឆន្ទៈ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា។

AZUMA & Co.,Ltd. ជាសហគ្រាសជប៉ុនសុទ្ធសាធ ដែលរូបខ្ញុំ Yosuke SASAKI ជាជនជាតិជប៉ុន ទទួលកាន់កាប់លើភាគហ៊ុន ១00 ភាគរយ និងមានតួនាទីជាប្រធាននាយក នៃសហគ្រាស AZUMA & Co.,Ltd.




យើងខ្ញុំមានកិត្តិយសក្រៃលែង ក្នុងនាមជានីតិបុគ្គលនៃសហគ្រាស AZUMA & Co.,Ltd. ដែលបានចូលរួមចំណែកក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន និងថែរក្សាអ្នកជំនាន់ក្រោយក៏ដូចជា ជួយលើកកម្ពស់កម្រិតស្តង់ដារ ការរស់នៅរបស់ពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើងៗ នៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែក លើគោលការណ៍ តម្លាភាព ប្រសិទ្ធភាព និងការផ្តល់សេវាហិរញ្ញប្បទាន ប្រកបដោយនិរន្តរភាពយូរអង្វែងរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី យើងខ្ញុំ។

# រចនាសម្ព័ន្ធ



ម្ចាស់ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
នាយកប្រតិបត្តិ
ទីប្រឹក្សានាយកប្រតិបត្តិ
នាយករងប្រតិបត្តិ
គណៈកម្មការឥណទាន
គណៈកម្មការប្រឹក្សាវិន័យ
គណៈកម្មការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា
គណៈកម្មការដឹកនាំអនុវត្តព័ត៌មានវិទ្យា
គណៈកម្មការយុទ្ធសាស្ត្រព័ត៌មានវិទ្យា
នាយកដ្ឋានទីផ្សារ
នាយករងនាយកដ្ឋានទីផ្សារ
ប្រធានផ្នែកទីផ្សារ
មន្ត្រីឌីហ្សាញ
នាយកដ្ឋានប្រតិបត្តិការ
នាយករងនាយកដ្ឋានប្រតិបត្តិការ
មន្ត្រីប្រតិបត្តិការជាន់ខ្ពស់
មន្ត្រីប្រតិបត្តិការ ២ នាក់
នាយកដ្ឋានហិរញ្ញវត្ថុ នាយក នាយកដ្ឋាន
គណនេយ្យករជាន់ខ្ពស់
គណនេយ្យករ ៣ នាក់
នាយកដ្ឋានឥណទាន នាយក នាយកដ្ឋាន
នាយករងនាយកដ្ឋានឥណទាន
មន្ត្រីវិភាគឥណទានជាន់ខ្ពស់
មន្ត្រីដោះស្រាយបំណុលជាន់ខ្ពស់
សាខាការិយាល័យកណ្តាល នាយកសាខា
សាខាខណ្ឌព្រែកព្នៅ នាយកសាខា
សាខាខណ្ឌពោធិ៍សែនជ័យ នាយកសាខា
សាខាក្រុងច្បារមន នាយកសាខា
សាខាក្រុងដូនកែវ នាយកសាខា
នាយកដ្ឋានព័ត៌មានវិទ្យា នាយក នាយកដ្ឋាន
នាយករងនាយកដ្ឋានព័ត៌មានវិទ្យា
មន្ត្រីព័ត៌មានវិទ្យាជាន់ខ្ពស់
មន្ត្រីព័ត៌មានវិទ្យា
នាយកដ្ឋានធនធានមនុស្សរដ្ឋបាល នាយក នាយកដ្ឋាន
មន្ត្រីហ្វឹកហ្វឺន និងជ្រើសរើសជាន់ខ្ពស់
មន្ត្រីធនធានមនុស្សនិងរដ្ឋបាល
នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម នាយក នាយកដ្ឋាន
មន្ត្រីច្បាប់ និងប្រតិបត្តិតាម
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
មន្ត្រីសវនកម្មផ្ទៃក្នុង

# ក្រុមប្រឹក្សាភិបាល



**លោក ច្រឹក ផល្លី** / ប្រធានក្រុមប្រឹក្សាភិបាល

លោក ច្រឹក ផល្លី កើតនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល ក្រោយមកលោកត្រូវបានតែងតាំង និងទទួលស្គាល់ជាប្រធានក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ រហូតមកដល់ពេលបច្ចុប្បន្ន។ លោកមានបទពិសោធន៍ជាង ១៨ឆ្នាំ ខាងផ្នែកគ្រប់គ្រង ដែលក្នុងរយៈពេល ៥ឆ្នាំ លោកបានបំពេញតួនាទីជាប្រធានគ្រប់គ្រងផ្នែកទីផ្សារនៅក្រុមហ៊ុន Futaba Co., Ltd ក្នុងឆ្នាំ២០០៧ លោកត្រូវបានតែងតាំងជានាយកចាត់ការទូទៅ ហើយបានបម្រើការងាររហូតមកដល់បច្ចុប្បន្ននេះ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យន័រតុន។



**លោក យូស្សូកេ សាសាគី** / សមាជិកក្រុមប្រឹក្សាភិបាល

លោក **យូស្សូកេ សាសាគី** កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៨៣ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦។ ក្រុមហ៊ុន AZUMA & CO., LTD ជាក្រុមហ៊ុនជប៉ុន និងជាម្ចាស់ភាគហ៊ុន ១០០ ភាគរយ ដែលតំណាងស្របច្បាប់ដោយ លោក យូស្សូកេ សាសាគី មានតួនាទីជាប្រធាននាយក។

ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន មានគោលគំនិតស្របគ្នាក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មីតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

## លោក ជូនីជី សាសាគី / សមាជិកក្រុមប្រឹក្សាភិបាល



លោក **ជូនីជី សាសាគី** កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៤៩ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជា សមាជិកក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។ លោក ជូនីជី សាសាគី បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យតូក្យូ នៅឆ្នាំ១៩៧៥ បច្ចុប្បន្នជាប្រធាន និងជាភាគទុនិក ១០០ ភាគរយ នៃក្រុមហ៊ុន FutureBud International Co., Ltd នៃប្រទេសជប៉ុន។

## លោក ម៉ូតូ ហាម៉ាដា / សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ



លោក **ម៉ូតូ ហាម៉ាដា** មានសញ្ញាតិជប៉ុន កើតនៅឆ្នាំ១៩៤៨ នៅទីក្រុង KANAGAWA ប្រទេសជប៉ុន។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សា ផ្នែកសេដ្ឋកិច្ច នៅសាកលវិទ្យាល័យពាណិជ្ជកម្ម KOBE (មហាវិទ្យាល័យសេដ្ឋកិច្ច KOBE) ក្នុងឆ្នាំ១៩៧០។ លោកមានបទពិសោធន៍ច្រើនជាង ១៥ឆ្នាំ ក្នុងការវិនិយោគក្រៅប្រទេស និង ២០ឆ្នាំ សម្រាប់ការគ្រប់គ្រងក្រុមហ៊ុន ដែលមានសម្ព័ន្ធភាពនៅក្រៅប្រទេស និង ៥ឆ្នាំ សម្រាប់ការពិគ្រោះយោបល់ និងជួយគម្រោងក្រៅប្រទេស របស់ក្រុមហ៊ុនខ្នាតតូច និងមធ្យម។

## លោក ង៉ែត សុវណ្ណារ៉ូ / សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ



លោក **ង៉ែត សុវណ្ណារ៉ូ** មានសញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៥៩ ក្នុងខេត្តតាកែវ នៃប្រទេសកម្ពុជា។ លោកត្រូវបានតែងតាំងជា សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកកសិកម្ម ពីសាកលវិទ្យាល័យមិត្តភាពនៃប្រជាជនម៉ូស្គូ នៃអាហារូបករណ៍ ផ្នែកអនុបណ្ឌិតផ្តល់ដោយរដ្ឋាភិបាលរុស្ស៊ីក្នុងឆ្នាំ ១៩៨៧។ លោកមានបទពិសោធន៍ច្រើនជាង ២៥ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩២ ក្នុងមុខតំណែងប្រធានគណនេយ្យ និងរយៈពេល ៨ឆ្នាំ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន នៃក្រសួងផែនការ។

# គណៈគ្រប់គ្រង

## លោក អ៊ុំ ពិសិដ្ឋ / នាយកប្រតិបត្តិ



លោក **អ៊ុំ ពិសិដ្ឋ** បានចាប់ផ្តើមអាជីពការងាររបស់លោកជាមួយ ហ្វូតាបា នៅចុងឆ្នាំ ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន បន្ទាប់មកនៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិ ដែលត្រូវទទួលបន្ទុក គ្រប់គ្រង និងមើលការខុសត្រូវលើនាយកដ្ឋានចំនួនបី គឺនាយកដ្ឋានឥណទាន នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានទីផ្សារ។ លោកបានបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រផ្នែកគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ទទួលបានសញ្ញាបត្រភាសាអង់គ្លេសថ្នាក់ IEAP ពីសាកលវិទ្យាល័យ បញ្ញាសាស្រ្តកម្ពុជា ហើយបានចូលរួមវគ្គបណ្តុះបណ្តាលសន្និសិទ និងសិក្ខាសិលាជាច្រើនដែលទាក់ទងទៅនឹងការអភិវឌ្ឍន៏វិស័យអចលនទ្រព្យ ការគ្រប់គ្រងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ ចំពោះបទពិសោធន៍ការងារ លោកបានចំណាយពេលជាង ១៧ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយ និងមុខតំណែងជាច្រើនដូចជា មន្ត្រីសាខា នាយកសាខា នាយកគ្រប់គ្រងតំបន់ នាយក-នាយកដ្ឋានប្រតិបត្តិការ នាយក-នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង នាយកគ្រប់គ្រងឥណទាន នាយកនាយកដ្ឋានឥណទាន។ លោកក៏បានចំណាយពេលជាង បីឆ្នាំ បម្រើការងារនៅវិស័យទូរគមនាគមន៍ផងដែរ។ លោក អ៊ុំ ពិសិដ្ឋ ត្រូវបានតែងតាំងជា នាយកប្រតិបត្តិ ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះតទៅ។

## បណ្ឌិត ចាប រតនា / ទីប្រឹក្សានាយកប្រតិបត្តិ



បណ្ឌិត **ចាប រតនា** បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងខែមករា ឆ្នាំ២០១៥ ជាទីប្រឹក្សាហិរញ្ញវត្ថុក្នុងស្រុក បន្ទាប់មកគាត់ក៏មកកាន់តំណែងជា នាយករងនាយកប្រតិបត្តិ នៅខែតុលា ឆ្នាំ២០១៥។ គាត់បានបញ្ចប់ថ្នាក់ បណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតគ្រប់គ្រង ការអប់រំនៅសាកលវិទ្យាល័យ បៀលប្រាយ។ អស់រយៈពេលជាង ២៥ឆ្នាំ គាត់ទទួលបានបទពិសោធន៍ ការងារយ៉ាងច្រើនដូចជា អ្នកបកប្រែភាសា រដ្ឋបាល អ្នកគ្រប់គ្រងគម្រោង និងជាអ្នកប្រឹក្សាយោបល់ក្នុងស្រុក ដែលមានទំនាក់ទំនងជាមួយនឹងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុង ក្រសួងគ្រប់ខេត្ត-ក្រុង រួមជាមួយ នឹងដៃគូ អភិវឌ្ឍ អង្គការសហប្រជាជាតិ, IO, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជន ក្នុងផ្នែកអភិវឌ្ឍផែនការថ្នាក់ជាតិ, ហិរញ្ញវត្ថុ ស្ថិតិ ការអប់រំ M&E, Health based UNTAC, WHO-Ministry of Health, and UN-Ministry of Planning.

## លោក ព្រាប កណ្ដឹង / នាយករងនាយកប្រតិបត្តិ



លោក **ព្រាប កណ្ដឹង** បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ (Master of Business Specializing in Finance) ពីសាកលវិទ្យាល័យ Charles Sturt University នៃប្រទេសអូស្ត្រាលី និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅសាកល វិទ្យាល័យជាតិគ្រប់គ្រង។ លោកមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ដែលពាក់ព័ន្ធទៅនឹងវិស័យធនាគារ និង ហិរញ្ញវត្ថុ ការសិក្សាក៏ដូចជាបទពិសោធន៍ការងារ បានធ្វើអោយគាត់មានការអភិវឌ្ឍ ជាបន្តបន្ទាប់នូវភាពរីកចម្រើននៃអាជីពការងាររបស់គាត់។ មុនពេល គាត់ចូលរួមបម្រើការងារជាមួយ **ហ្វូតាបា** លោកមានបទពិសោធន៍ការងារជាច្រើនពាក់ពន្ធ័ទៅ នឹងការគ្រប់គ្រងគណនេយ្យ ប្រឹក្សាយោបល់ផ្នែកគណនេយ្យ និងជានាយកនាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ។ លោកបានចូលរួមជាមួយ ហ្វូតាបា នៅឆ្នាំ២០១៥ ដែលមានតួនាទីជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ នៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងតួនាទីជាជំនួយការនាយកប្រតិបត្តិ ដែលទទួលខុសត្រូវទៅលើនាយកដ្ឋានចំនួន បី ដូចជា នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល។ លោក ព្រាប កណ្ដឹង ត្រូវបានតែងតាំងជា នាយករងប្រតិបត្តិ ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះតទៅ។

## លោក លឹម សំបូរ / នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល



លោក **លឹម សំបូរ** កើតនៅខែមិថុនា ឆ្នាំ១៩៨១ បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងមុខតំណែងជា នាយក នាយកដ្ឋានទីផ្សារ។ បន្ទាប់បម្រើការងាររយៈពេល ២ឆ្នាំ លោកត្រូវបានផ្លាស់ប្តូរមុខតំណែងជា នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ដោយទទួលខុសត្រូវក្នុងការគ្រប់គ្រងរៀបចំចាត់ចែង និងបង្កើតគោលនយោបាយ នីតិវិធីការងារនានាពាក់ព័ន្ធនឹងកិច្ចការ ធនធានមនុស្ស និងផ្នែករដ្ឋបាល។ នៅមុនពេលចាប់ផ្តើមអាជីពមួយនេះ លោកធ្លាប់មានបទពិសោធន៍រយៈពេលជាង ១៤ឆ្នាំ បម្រើការងារជាមួយធនាគារធំៗចំនួនពីររួមមាន ៖ ធនាគារបរទេសថ្នាក់តំបន់ និងធនាគារក្នុងស្រុកមួយ ដែលមានបណ្តាញប្រតិបត្តិការធំជាងគេផងដែរ។ ជាមួយបទពិសោធន៍ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ លោកធ្លាប់បានទទួលខុសត្រូវមុខងារដូចជា ប្រធានទំនាក់ទំនង ប្រធានផ្នែកឥណទាន ភតិសន្យា អនុប្រធានផ្នែក ឥណទាន និង តួនាទីជាច្រើនទៀតដែលលោកបានចំណាយពេលជាង ១០ឆ្នាំ ចូលរួមក្នុងសកម្ម ភាពជាច្រើននៃការលក់ជួរមុខ។ ដោយ ឡែក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យបៀលប្រាយ ផ្នែកហិរញ្ញវត្ថុ និងធនាគារក្នុង ឆ្នាំ២០០៨។

**លោក គង់ សារ៉ាត់** / នាយក នាយកដ្ឋានព័ត៌មានវិទ្យា



លោក **គង់ សារ៉ាត់** ជាជនជាតិខ្មែរ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់ គ្រងក្នុងឆ្នាំ២០១១ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា និងផ្នែកអក្សរសាស្ត្រអង់គ្លេសផងដែរ។ ជាមួយនិងអតីតភាពការងារ លោកមានតួនាទីជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យានៃធនាគារពាណិជ្ជដ៏ធំមួយនៅកម្ពុជា ដែលទទួលខុសត្រូវលើផ្នែកប្រព័ន្ធធនាគារស្នូលប្រព័ន្ធ Card និង SWIFT ជាមួយនិងមុខជំនាញបច្ចេកទេសជាច្រើនដូចជាការរៀបចំដំណើរការប្រព័ន្ធធនាគារ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញ Network ប្រកបដោយសុវត្ថិភាព និងការរៀបចំគោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។ នៅដើមឆ្នាំ ២០១៦ គាត់បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** ជានាយករងផ្នែកព័ត៌មានវិទ្យា ក្រោយមកបានរយៈពេល ៦ខែ បន្ទាប់គាត់ត្រូវបានដំឡើងតួនាទី ជានាយក នាយកដ្ឋានព័ត៌មានវិទ្យា។ គាត់ជាអ្នកចាប់ផ្តើមដំបូងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ Network រៀបចំមជ្ឈមណ្ឌលទិន្នន័យ មជ្ឈមណ្ឌលទិន្នន័យសង្គ្រោះបន្ទាន់ គោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា ក៏ដូចជាគោលនយោបាយសុវត្ថិភាពទិន្នន័យសម្រាប់គ្រឹះស្ថាន **ហ្វូតាបា** ចាប់តាំងពីការកកើតដំបូងនៃគ្រឹះស្ថាន។ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ គាត់មានបទពិសោធន៍ផ្នែកព័ត៌មានវិទ្យាជាង ១0ឆ្នាំមកហើយ។

**លោក ស ភារុំ** / នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម



លោក **ស ភារុំ** បានចូលបម្រើការងារក្នុងគ្រឹះស្ថាន **ហ្វូតាបា** ក្នុងតួនាទីជា នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ចាប់ពីថ្ងៃ ទី០១ ខែកញ្ញា ឆ្នាំ២០១៧។ មុនពេលគាត់ចូលបម្រើការងារនៅ **ហ្វូតាបា** លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន ក្នុងតួនាទីចុងក្រោយ ជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម ហើយគាត់បានចាប់ផ្តើមការងារក្នុងតួនាទី ជាច្រើនជាមួយគ្រឹះស្ថាន ចម្រើន ដែលចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ២០០៩ ជាមន្ត្រីឥណទាន និងក្លាយជាមន្ត្រីសវនកម្មផ្ទៃក្នុង ក្នុងខែកុម្ភៈ ឆ្នាំ២០១០។ ក្រោយមក គាត់ត្រូវបានតែងតាំងជាប្រធានសាខា នៅខែវិច្ឆិកា ឆ្នាំ ២០១០ និងប្តូរទៅជាមន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ ក្នុងខែមិថុនា ឆ្នាំ ២០១២។ បន្ទាប់មក គាត់ក៏ត្រូវបានដំឡើងទៅជាប្រធានផ្នែកច្បាប់ និងប្រតិបត្តិតាម ក្នុងខែមិថុនា ឆ្នាំ២០១៣ និងជាប្រធាននាយកដ្ឋានច្បាប់ ក្នុងខែមករា ឆ្នាំ២០១៥ ហើយបានទទួលខុសត្រូវក្នុងតួនាទីចុងក្រោយជា ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម។ ហើយគាត់ក៏ធ្លាប់បម្រើការ ងារនៅសណ្ឋាគារ Feeling Home ជាអ្នកទទួលភ្ញៀវ រយៈពេល ១ឆ្នាំ និងធ្វើការជាអ្នកស្ម័គ្រចិត្ត ជាមួយអង្គការទស្សនៈពិភពលោកនៅស្រុករយៈពេល ៤ឆ្នាំផងដែរ។ គាត់បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង បរិញ្ញាបត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យធនធានមនុស្ស។ ក្នុងតួនាទី និងការទទួលខុសត្រូវនោះ គាត់មានបទពិសោធន៍ ក្នុងតួនាទីផ្សេងៗគ្នារយៈពេល ៩ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

## លោក យ៉ាត ប៊ុនជា / នាយក នាយកដ្ឋានឥណទាន



លោក **យ៉ាត ប៊ុនជា** បច្ចុប្បន្នបានចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី តួនាទីជា នាយក នាយកដ្ឋានឥណទាន។ មុនចូលបម្រើការនៅគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី លោកធ្លាប់កាន់មុខតំណែងជាច្រើនក្នុងវិស័យហិរញ្ញវត្ថុ ដូចជា៖ មន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ នាយកផ្នែកឥណទាន នាយកសាខា នាយកសាខាខេត្ត នាយកប្រតិបត្តិការ និងជានាយកគ្រប់គ្រងទូទៅផងដែរ លោកមានជំនាញ និងបទពិសោធន៍ការងារជាមួយវិស័យ NGO និង មីក្រូហិរញ្ញវត្ថុអស់រយៈពេលជាង២៥ឆ្នាំ។ លោកក៏ធ្លាប់ធ្វើការងារជាមួយអ៊ុនតាក់ (UNTAC) ក្នុងតួនាទីជាអ្នកបកប្រែ និងជាអ្នកសង្កេតការការបោះឆ្នោតក្នុងឆ្នាំ១៩៩៣។ លោកធ្លាប់បំពេញការងារជាមន្ត្រីរាជការ ជាគ្រូវិទ្យាល័យ មុខវិជ្ជាបង្រៀនជីវវិទ្យា និងភាសាអង់គ្លេស។ លោកបានបញ្ចប់កថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ឯកទេសគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យបៀលប្រាយក្នុងឆ្នាំ២០០៩។ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងជំនាញវគ្គខ្លីៗជាច្រើន ជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងវគ្គបណ្តុះបណ្តាលពិសេសផ្សេងទៀត ដូចជា៖ Credit Unions Management រៀបចំដោយ Asian Confederation of Credit Unions (ACCU) និង Credit Union League of Thailand Limited (CULT) នៅប្រទេសថៃ។

## លោក កន វិចិត្រ / នាយក នាយកដ្ឋានហិរញ្ញវត្ថុ



លោក **កន វិចិត្រ** កើតនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៧៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបៀលប្រាយក្នុងឆ្នាំ ២០០៨។ នៅឆ្នាំ ១៩៩៥ លោកបានចូលបម្រើការងារនៅធនាគារឯកជនមួយ នៅទីក្រុងភ្នំពេញដំបូងជាបុគ្គលិកធនាគារ ហើយលោកត្រូវបានគេដំឡើងតំណែងជាបន្តបន្ទាប់ និងចុងក្រោយ គាត់ជាជំនួយការប្រធាននាយកដ្ឋានហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០០៩ លោកបានប្តូរមកបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ របស់វិនិយោទុនកូរ៉េ តួនាទីជាអ្នកគ្រប់គ្រងនាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ។ ហើយបន្ទាប់មកក្នុងឆ្នាំ ២០១៨ លោកបានផ្លាស់ការងារ មកចូលរួមជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មួយដែលជាម្ចាស់ភាគទុនិករបស់ខ្មែរ នៅទីនោះលោកជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ហើយបន្ទាប់រហូតដល់ឆ្នាំ២០២១ លោកត្រូវបានដំឡើងតួនាទីជាអនុប្រធានគ្រប់គ្រងទូទៅ។ លោកបានរៀបចំការងារនិងចាត់ចែង សកម្មភាពប្រតិបត្តិការប្រចាំថ្ងៃគ្រប់នាយកដ្ឋានទាំងអស់របស់គ្រឹះស្ថាន។ លោក កន វិចិត្រ បានចូល រួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងវិស័យធនាគារ និង មីក្រូហិរញ្ញវត្ថុ ដូចជានៅសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា CMA, ក្រុមហ៊ុន Credit Bureau Cambodia Ltd., CBC, ជាមួយធនាគារជាតិ នៃកម្ពុជា NBC សាលាជាតិពន្ធដាកម្ពុជា NTS ក្នុងឆ្នាំ២០២២ លោកបានចូលរួម វគ្គបណ្តុះបណ្តាលរយៈពេល៦ខែ CIFRS for SMEs at CamEd Business School និងក្រសួងពាក់ព័ន្ធផ្សេងៗ ក៏ដូចជាចូលរួមសិក្ខាសាលាជាច្រើនទៀត។ រហូតមកដល់ពេលនេះ លោកបានចំណាយពេលជាមួយអាជីពការងាររបស់លោកជាង ២០ ឆ្នាំក្នុងវិស័យធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះ ហើយនៅ ដើមខែធ្នូ ឆ្នាំ២០២៣ ថ្មីៗនេះ លោកបានប្តូរមកបម្រើការងារ ជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ដែលមានតួនាទីជា នាយក នាយកដ្ឋានហិរញ្ញវត្ថុ ។



# សុបិនក្លាយជាការពិត

# សមិទ្ធផលអាជីវកម្ម

- សមិទ្ធផលឥណទានតាមវិស័យ
- សមិទ្ធផលឥណទានតាមផលិតផល
- ចំណាត់ថ្នាក់ប្រភេទឥណទាន
- ចំណាត់ថ្នាក់ប្រភេទផលិតផល



## ឥណទានកសិកម្ម

. ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

. ទំហំឥណទានរហូតដល់ : ២០០.០០០ ដុល្លារ

. រយៈពេលរហូតដល់ : ១០ ឆ្នាំ

# សមិទ្ធផលឥណទានតាមវិស័យ

## ចំនួនគណនី

| វិស័យ | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២១ | ៤២ | ៣០ |
| ជំនួញ និងពាណិជ្ជកម្ម | ១១២ | ១១១ | ១១០ |
| សំណង់ | ៤៤ | ៥៧ | ៦៨ |
| ការដឹកជញ្ជូន | ៣៤ | ៣៦ | ៣៥ |
| សេវាកម្ម | ៣៣ | ១៥ | ១៨ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៦៣៩ | ៥២៨ | ៤៩០ |
| ប្រភេទផ្សេងៗទៀត | - | - | - |
| សរុប | ៨៨៣ | ៧៨៩ | ៧៥១ |

## ផលបត្រឥណទានសរុប

| វិស័យ | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២១ ដុល្លារអាមេរិក |
|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣០១.៦៥៣ | ៦០២.៥០៦ | ៤២៤.៩៦៥ |
| ជំនួញ និងពាណិជ្ជកម្ម | ២.២១៣.០០១ | ២.៣៥៦.០៦៨ | ២.៤៨០.៣៥៨ |
| សំណង់ | ៦៧២.៦២៣ | ៩២៣.០៨២ | ១.២៥៩.៣២១ |
| ការដឹកជញ្ជូន | ៥៣២.០៣៨ | ៦៣២.៤៤៤ | ៦២៥.១២៥ |
| សេវាកម្ម | ៧៥៥.០៩២ | ៣៧៧.៣៦៥ | ៤៤៩.១៣២ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៩.៩០៨.៦៦៩ | ៨.៤០៤.៤៥៤ | ៨.១៤៨.៦៣៣ |
| ប្រភេទផ្សេងៗទៀត | - | - | - |
| សរុប | ១៤.៣៨៣.០៧៦ | ១៣.២៩៥.៩២០ | ១៣.៣៨៧.៥៣៤ |

# សមិទ្ធផលឥណទានតាមផលិតផល

## ចំនួនឥណទាន

| ផលិតផល | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ឥណទានអាជីវកម្ម | ២០៤ | ១៨៤ | ១៩៩ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៤០៨ | ៣២៤ | ២៧១ |
| ឥណទានកសិកម្ម | ៣២ | ៤០ | ៣១ |
| ឥណទានគេហដ្ឋាន | ១៨០ | ១៨៥ | ១៩៦ |
| ឥណទានបុគ្គលិក | ៣៥ | ៣៣ | ៣៥ |
| ឥណទានសិក្សា | ៣ | ៣ | ៣ |
| ឥណទាននិយោជិត | ២១ | ២០ | ១៦ |
| សរុប | ៨៨៣ | ៧៨៩ | ៧៥១ |

## ផលបត្រឥណទានសរុប

| ផលិតផល | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | ២០២១ ដុល្លារអាមេរិក |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៣.៩០៣.៣១៨ | ៣.៨៨៩.១២៤ | ៤.២៥៧.៣៥៧ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៥.៧១០.៤៦៩ | ៤.២២៣.៨៦៥ | ៣.៦៣៣.០៧៣ |
| ឥណទានកសិកម្ម | ៤៣៥.៩៨៣ | ៥៨២.៨២១ | ៤៦២.៣៩៧ |
| ឥណទានគេហដ្ឋាន | ៤.០១៣.៩៥៣ | ៤.២៦៧.៨១៨ | ៤.៦០៧.២៧៣ |
| ឥណទានបុគ្គលិក | ២៨០.523 | ២៦៥.៧៩៧ | ៤០២.៥៥០ |
| ឥណទានសិក្សា | ២.៩៤៨ | ៧៩២ | ៦៥០ |
| ឥណទាននិយោជិត | ៣៥.៨៨២ | ៣៧.៤១៤ | ២៤.០៥៤ |
| សរុប | ១៤.៣៨៣.០៧៦ | ១៣.២៦៧.៦៣១ | ១៣.៣៨៧.៣៥៤ |

# ចំណាត់ថ្នាក់ប្រភេទឥណទាន

### ផលបត្រឥណទានសរុប

| ប្រភេទ | ២០២៣ | ២០២២ | កំណើន (%) |
|---|---|---|---|
| ឥណទានខ្នាតតូចបំផុត | ២៩៣.៨១៣ | ២៩៧.៦៣១ | (១.២៨%) |
| ឥណទានខ្នាតតូច | ៥.០៨៣.៣៨២ | ៤.៤២២.៨១៦ | ១៤.៩៤% |
| ឥណទានខ្នាតមធ្យម | ៨.២៩៣.១៥១ | ៧.៥៩៨.៣១៨ | ៩.១៤% |
| ឥណទានខ្នាតធំ | ៧១២.៧៣១ | ៩៧៧.១៥៦ | (២៧.០៦%) |
| សរុប | ១៤.៣៨៣.០៧៦ | ១៣.២៩៥.៩២០ | ៨.១៨% |

# ចំណាត់ថ្នាក់ប្រភេទផលិតផល

### ផលបត្រឥណទានសរុប

| ផលិតផល | ២០២៣ ដុល្លារអាមេរិក | ២០២២ ដុល្លារអាមេរិក | កំណើន (%) |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៣.៩០៣.៣១៨ | ៣.៨៩៧.៤១៦ | ០.១៥% |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៥.៧១០.៤៦៩ | ៤.២៣២.៨៧១ | ៣៤.៩១% |
| ឥណទានកសិកម្ម | ៤៣៥.៩៨៣ | ៥៨៤.០៦៣ | (២៥.៣៥%) |
| ឥណទានគេហដ្ឋាន | ៤.០១៣.៩៥៣ | ៤.២៧៦.៩១៨ | (៦.១៥%) |
| ឥណទានបុគ្គលិក | ២៨០.៥២៣ | ២៦៦.៣៦៤ | ៥.៣២% |
| ឥណទានសិក្សា | ២.៩៤៨ | ៧៩៣ | ២៧១.៥៧% |
| ឥណទាននិយោជិត | ៣៥.៨៨២ | ៣៧.៤៩៤ | (៤.៣០%) |
| សរុប | ១៤.៣៨៣.០៧៦ | ១៣.២៩៥.៩២០ | ៨.១៨% |

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

- ការបណ្តុះបណ្តាលខាងក្នុង
- ការបណ្តុះបណ្តាលខាងក្រៅ
- សិក្ខាសាលាប្រចាំឆ្នាំ



## ឥណទានគេហដ្ឋាន

. ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

. ទំហំឥណទានរហូតដល់ : ២០០.០០០ ដុល្លារ

. រយៈពេលរហូតដល់ : ១០ ឆ្នាំ

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតផែនការសកម្មភាពសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៅក្នុងបរិយាកាសទីផ្សារដែលមានការប្រកួតប្រជែងខ្ពស់ ដើម្បីយកឈ្នះលើស្ថានភាពបច្ចុប្បន្ន និងធានាបាននូវការពេញចិត្តរបស់ អតិថិជនរបស់ខ្លួន។ ការបណ្តុះបណ្តាលបុគ្គលិក គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយដែលអ្នកគ្រប់គ្រងកំពូលតែងតែគាំទ្រដើម្បីកែលម្អចំណេះដឹង និងជំនាញរបស់បុគ្គលិក។ ការបណ្តុះបណ្តាលទាំងបុគ្គលិកចូលថ្មី និងបុគ្គលិកបច្ចុប្បន្ន ត្រូវបានកំណត់និងសម្រប សម្រួលដោយនាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល ជាមួយនាយកដ្ឋានផ្សេងទៀត។

- ការបណ្តុះបណ្តាលខាងក្នុង

សម្រាប់ឆ្នាំ២០២៣នេះ ការបណ្តុះបណ្តាលខាងក្នុងត្រូវបានរៀបចំឡើងមានចំនួនសរុប ៣៤លើក ដែលក្នុងនោះបុគ្គលិកចូលថ្មីមានចំនួន ១៣លើក និងបុគ្គលិកកំពុងបម្រើការងារមានចំនួន ២១លើក ផងដែរ។



កម្រងរូបភាពការបណ្តុះបណ្តាលខាងក្នុង

## - ការបណ្តុះបណ្តាលខាងក្រៅ

ដើម្បីបន្តការងាររបស់ **ហ្វូតាបា** ឆ្ពោះទៅរកកំណើនប្រកបដោយនិរន្តរភាព អ្នកគ្រប់គ្រង និងបុគ្គលិកត្រូវបន្តបញ្ជូនទៅសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលខាងក្រៅ។ **ហ្វូតាបា** បានជំរុញយ៉ាងខ្ជាប់ខ្ជួន សម្រាប់ការអនុវត្តជាទៀងទាត់នៃយុទ្ធសាស្រ្តនេះ ហើយចាត់ទុកវាជាអាទិភាពកំពូល។ ជាក់ស្តែង **ហ្វូតាបា** បានលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ខ្លួនឱ្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនៅខាងក្រៅ ក៏ដូចជាសិក្ខាសាលាបន្ថែមទៀតចំនួន ១៤ ដងសម្រាប់ឆ្នាំ ២០២៣។




កម្រងរូបភាពការបណ្តុះបណ្តាលខាងក្រៅ

## - សិក្ខាសាលាប្រចាំឆ្នាំ

សិក្ខាសាលាប្រចាំឆ្នាំគឺជាព្រឹត្តិការណ៍សំខាន់មួយទៀតដែលអ្នកគ្រប់គ្រងរបស់ **ហ្វូតាបា** គ្រោងធ្វើជារៀងរាល់ឆ្នាំ។ តាមរយៈសិក្ខាសាលានេះ បុគ្គលិក និងថ្នាក់ដឹកនាំការិយាល័យសាខាបានមកជួបជុំគ្នាដើម្បីពិភាក្សា និងអនុវត្តគំនិតផ្តួចផ្តើមថ្មីៗ ក៏ដូចជាស្វែងយល់អំពីលទ្ធផលអាជីវកម្មទាំងមូលបន្ទាប់ពីការខិតខំប្រឹងប្រែងអស់រយៈពេលមួយឆ្នាំ។ អ្នកគ្រប់គ្រងថ្នាក់លើអាចផ្តល់ដំបូន្មានដ៏ឈ្លាសវៃបន្ថែមទៀតអំពីរបៀបបំពេញការងារដើម្បីបង្កើនភាពជោគជ័យ។

វត្តមានរបស់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ បានធ្វើឱ្យកម្មវិធីសិក្ខាសាលាឆ្នាំ ២០២៣ មានអារម្មណ៍កក់ក្តៅដូចជាគ្រួសារធំមួយ។ សិក្ខាសាលាប្រចាំឆ្នាំ ២០២៣នេះ ត្រូវបានប្រារព្ធឡើងនៅរាជធានីភ្នំពេញ និងមានប្រធានបទ «សិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅអនុវត្តន៍សម្រាប់ធ្វើឆ្នាំបន្ទាប់» ដោយមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងបុគ្គលិកសរុបចំនួន ៩០នាក់។





















កម្រងរូបភាពសិក្ខាសាលាប្រចាំឆ្នាំ

# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

- ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម
- សវនកម្មផ្ទៃក្នុង



### ឥណទានអាជីវកម្ម

. ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
. ទំហំឥណទានរហូតដល់ : ២០០.០០០ ដុល្លារ
. រយៈពេលរហូតដល់ : ១០ ឆ្នាំ

# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

និយ័តករ ក្រុមហ៊ុនសវនកម្មឯករាជ្យ និងអ្នកពិគ្រោះយោបល់ ជាផ្នែកមួយនៃការត្រួតពិនិត្យលើប្រតិបត្តិការរបស់ស្ថាប័នពីខាងក្រៅ ដែលអាចបង្ហាញឱ្យឃើញថា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានចំណុចខ្វះខាត កំណត់ហានិភ័យកើតឡើងនានា និងកំណត់ច្បាស់ពីតម្រូវការរបស់ស្ថាប័នដែលត្រូវកែលម្អ។ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម បានបន្តពង្រឹងការអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ដោយផ្តោតលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានានៃការផ្តល់អាជ្ញាបណ្ណរបស់ធនាគារជាតិនៃកម្ពុជា និងការចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវការពង្រីកអាជីវកម្ម និងប្រតិបត្តិការរបស់គ្រឹះស្ថានប្រកបដោយភាពត្រឹមត្រូវពេញលេញស្របតាមច្បាប់ បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិនានានៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ សមាជិកក្រុមប្រឹក្សាភិបាល បានសម្រេចបង្កើតឱ្យមាននាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ដែលទទួលខុសត្រូវដោយនាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម គឺដើម្បីធានាថា ការគ្រប់គ្រងហានិភ័យដែលអាចកើតឡើង និងការប្រតិបត្តិតាមរបស់គ្រឹះស្ថាន ហ្វូតាបា មានភាពច្បាស់លាស់ដោយត្រូវត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃលើហានិភ័យទាំង ខាងក្នុង និងក្រៅដែលអាចមានការគំរាមកំហែង ឬផលប៉ះពាល់ដល់ប្រតិបត្តិការរបស់គ្រឹះស្ថាន ហ្វូតាបា និងធានាថាការអនុវត្ត និងនីតិវិធីត្រូវបានអនុវត្តន៍បានពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា។ ក្រៅពីនេះលោកក៏ទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យការអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុង នីតិវិធី និងគោលការណ៍ណែនាំនានា ទាក់ទងនឹងការអនុវត្តច្បាប់របស់គ្រឹះស្ថានរួមមានការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការ ប្រកាន់ខ្ជាប់នូវការអនុវត្តលើគោលការណ៍ដែលមានស្រាប់ ជាមួយនឹងបញ្ហានានាទាំងខាងក្នុង និងក្រៅពាក់ព័ន្ធនឹងការប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម។ ក្នុងគោលដៅវាស់វែង និងត្រួតពិនិត្យលើសមត្ថភាព និងបទពិសោធន៍ការងាររបស់អ្នកទទួលខុសត្រូវផ្នែកប្រតិបត្តិតាម បានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ដោយត្រូវមានវិញ្ញាបនបត្រការអនុលោមតាមបទប្បញ្ញត្តិទទួលស្គាល់ពីវិទ្យាស្ថាន ធនាគារ និងហិរញ្ញវត្ថុ ហើយត្រូវបន្តវិញ្ញាបនបត្រនេះនៅរៀងរាល់ ៣ឆ្នាំម្តង។ បន្ថែមលើនោះទៀត នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលត្រូវរាយការណ៍ និងសហការប្រតិបត្តិការជាមួយនាយកដ្ឋានស៊ើបការណ៍ហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជាផងដែរ។

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

គ្រឹះស្ថាន បានបង្កើតឱ្យមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងកម្រិតក្រុមប្រឹក្សាភិបាលដែលមានសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យជាប្រធាន។ នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ជាអ្នកសម្របសម្រួលដើម្បីពិភាក្សាអំពីរបាយការណ៍នៃការប្រតិបត្តិតាមជាមួយគ្រប់នាយកដ្ឋាន ឬគណៈគ្រប់គ្រង និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងភាពពេញលេញនៃការវិភាគហានិភ័យប្រតិបត្តិតាមដែលតម្រូវដោយច្បាប់ប្បញ្ញត្តិនានា។ រាល់ហានិភ័យប្រតិបត្តិតាមសំខាន់ៗត្រូវបានបង្ហាញ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ត្រឡប់មកវិញក្នុងការប្រតិបត្តិតាម និងដោះស្រាយឱ្យបានទាន់ពេលវេលា។ បន្ថែមលើនេះទៀត នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ក៏ជាសមាជិកនៃគណៈកម្មការក្នុងកម្រិតគណៈគ្រប់គ្រងដែល មានគណៈកម្មការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា គណៈកម្មការយុទ្ធសាស្ត្រព័ត៌មានវិទ្យា និងគណៈកម្មការដឹកនាំអនុវត្តន៍ព័ត៌មានវិទ្យា ដើម្បីត្រួតពិនិត្យ និងអនុវត្តន៍ឱ្យបានត្រឹមត្រូវលើផ្នែកព័ត៌មានវិទ្យា។

## ការប្រជុំ និងសមាជិកភាព

កិច្ចប្រជុំគណៈកម្មាធិការនេះត្រូវធ្វើឡើងយ៉ាងតិច ២ដងក្នុង១ឆ្នាំ ដែលមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់ សមាជិក។ គណៈកម្មាធិការនេះ ត្រូវមានសមាជិកយ៉ាងតិច ៣នាក់។ សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានសមាសភាពដូចខាងក្រោម៖


លោក ង៉ែត សុវណ្ណារ៉ូ
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
(ប្រធាន)


លោក Yosuke SASAKI
សមាជិកក្រុមប្រឹក្សាភិបាល
(សមាជិក)


លោក Junichi SASAKI
នាយកប្រតិបត្តិ/អភិបាល
(សមាជិក)


លោក អ៊ុំ ពិសិដ្ឋ
នាយកប្រតិបត្តិ
(កោះអញ្ជើញ)


លោក ព្រាប កណ្តឹង
នាយករងប្រតិបត្តិ
(កោះអញ្ជើញ)


លោក ស ភារុំ
នាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម
(លេខាធិការ)

- ភារកិច្ច និងការទទួលខុសត្រូវ
- ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ច្បាប់ និងប្រតិបត្តិតាម ក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់
- ត្រួតពិនិត្យលើការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវការវាយតម្លៃនៃមុខងារប្រតិបត្តិតាម ដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិនានា
- ពិនិត្យជាប្រចាំនូវបញ្ជីត្រួតពិនិត្យការប្រតិបត្តិតាមផ្ទៃក្នុង ដើម្បីកំណត់ពីហានិភ័យប្រតិបត្តិតាម និងចាត់វិធានការ និងផែនការសកម្មភាពបន្ត ក្នុងការគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- ពិចារណា និងពិនិត្យលើរបាយការណ៍សវនកម្មដែលបានរកឃើញពាក់ព័ន្ធផ្នែកប្រតិបត្តិតាម និងហានិភ័យផ្នែកច្បាប់ ដែលកំពុងកើតមានឡើង និងផលប៉ះពាល់នានា
- ត្រួតពិនិត្យនៃការប្រតិបត្តិតាមប្រកបដោយប្រសិទ្ធភាពលើការអនុវត្តនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា
- ធានាថា ការបណ្តុះបណ្តាលចាំបាច់ត្រូវបានផ្តល់ជូនដល់គ្រប់បុគ្គលិក និងដើម្បីធានាឱ្យបាននូវការយល់ដឹងនៃសកម្មភាពប្រតិបត្តិតាម រួមទាំងការយល់ដឹងនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យក្នុងគ្រឹះស្ថាន
- ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យក្នុងការតាមដាន និងវាយតម្លៃ លើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

# សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុង ត្រូវតែជាផ្នែកមួយឯករាជ្យក្នុងការត្រួតពិនិត្យ និងរាយការណ៍លើការអនុវត្តទូទៅរបស់ស្ថាប័ន។ ផ្នែកសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១៧ ទទួលខុសត្រូវដោយប្រធានផ្នែកសវនកម្មផ្ទៃក្នុង ហើយត្រូវបានផ្លាស់ប្តូរ និងបានទទួលស្គាល់ជាថ្មីពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុង នឹងទទួលខុសត្រូវក្នុងការធ្វើសវនកម្មផ្ទៃក្នុង និងត្រួតពិនិត្យប្រតិបត្តិការនានានៅក្នុងគ្រឹះស្ថាន ហ្វូតាបា ដោយត្រូវអនុវត្តទៅតាមផែនការសវនកម្ម ធ្វើបច្ចុប្បន្នភាពកម្មវិធីសវនកម្ម និងផ្តល់ការបណ្តុះបណ្តាលបុគ្គលិក ដែលជាតម្រូវការចាំបាច់ដើម្បីបង្កើនគុណភាពសវនកម្មរបស់ខ្លួន។ តាមគោលការណ៍ និងផែនការរបស់សវនកម្មផ្ទៃក្នុងយ៉ាងហោចណាស់ ៣ដងក្នុង ១ឆ្នាំ ត្រូវចុះធ្វើសវនកម្មនៅការិយាល័យសាខា និង ១ដងក្នុងមួយឆ្នាំតាមនាយកដ្ឋានសំខាន់ៗ។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុងត្រូវត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់គ្រឹះស្ថាន ហ្វូតាបា និងរាយការណ៍ដោយឯករាជ្យ និងដោយផ្ទាល់ទៅគណៈកម្មាធិការសវនកម្មផ្ទៃក្នុងក្នុងកម្រិតក្រុមប្រឹក្សាភិបាល។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៣ សវនកម្មផ្ទៃក្នុង ក៏បានរាយការណ៍នូវរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់ខ្លួនទៅសមាជិកក្រុមប្រឹក្សាភិបាលពីការអនុវត្តការងារ និងកំហុសឆ្គងនានានៃប្រតិបត្តិការគ្រឹះស្ថានរបស់ គណៈគ្រប់គ្រងនាយកដ្ឋាន និងការិយាល័យសាខានីមួយៗ។

ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង គ្រឹះស្ថាន ហ្វូតាបា បានបង្កើតគណៈកម្មាធិការចំនួន ២ រួមមាន គណៈកម្មាធិការសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

## គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីធានាអភិបាលកិច្ចសាជីវកម្មប្រកបដោយសុវត្ថិភាព និងត្រូវផ្តល់អំណាចពិសេសចាំបាច់ដែលត្រូវបានកំណត់ក្នុងគោលការណ៍ ដើម្បីសម្រេចគោលដៅរបស់ខ្លួន។ អំណាចតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មផ្ទៃក្នុងមានភាពទូលំទូលាយ និងគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា ១៣១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក៏ដូចជាមាត្រា ៨ នៃប្រកាសលេខ ធ៧-០៨-២១១ ស្តីពីអភិបាលកិច្ចរបស់ធនាគារ និងហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រធានគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ហើយក៏ត្រូវឆ្លើយនឹងសំណួរទាំងអស់ពីភាគទុនិកនៅក្នុងកិច្ចប្រជុំ។

## ការប្រជុំ និងសមាជិកភាព

កិច្ចប្រជុំគណៈកម្មាធិការសវនកម្មផ្ទៃក្នុង អាចប្រព្រឹត្តទៅបានក្នុងករណីមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់ សមាជិក ឬតាមសំណើរបស់សវនករផ្ទៃក្នុង ឬសវនករឯករាជ្យ ( ខាងក្រៅ ) ប្រសិនបើចាំបាច់។ សេចក្តីបញ្ជាក់ពីទីកន្លែង ពេលវេលា

និងរបៀបវារៈកិច្ចប្រជុំដែលត្រូវពិភាក្សាត្រូវបញ្ជូនទៅកាន់គ្រប់សមាជិក និងអ្នកពាក់ព័ន្ធដែលត្រូវចូលរួមប្រជុំឱ្យបានយ៉ាងតិចណាស់មុន ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ ឯកសារពាក់ព័ន្ធត្រូវផ្ញើទៅកាន់គ្រប់សមាជិក និង អ្នកចូលរួមផ្សេងទៀតក្នុងពេលជាមួយគ្នា។ កិច្ចប្រជុំវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមការពិនិត្យថាសមស្រប ប៉ុន្តែកិច្ចប្រជុំវិសាមញ្ញត្រូវធ្វើឡើងយ៉ាងតិច ២ (ពីរ) ដងក្នុង១ (មួយ) ឆ្នាំ គឺនៅក្នុងខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗទៅតាមស្ថានភាពជាក់ស្តែង។ ជាក់ស្តែងក្នុងឆ្នាំ២០២៣ កិច្ចប្រជុំគណៈកម្មាធិការនេះ បានប្រព្រឹត្តទៅដោយផ្ទាល់នៅការិយាល័យកណ្តាល លើកទី១ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ និងលើកទី២ តាមប្រព័ន្ធអេឡិចត្រូនិច កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣។

គណៈកម្មាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដោយមានសមាជិកយ៉ាងតិចបំផុត ៣ រូប។ ប្រធាននៃគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យរបស់ក្រុមហ៊ុន ហើយគ្រប់សមាជិកទាំងអស់ក៏ត្រូវតែមានភាពឯករាជ្យលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនផងដែរ។ សមាជិកគណៈកម្មាធិការសវនកម្មរួមមានដូចខាងក្រោម:

| | | |
|---|---|---|
| - លោក MOTOO HAMADA | ក្រុមប្រឹក្សាភិបាលឯករាជ្យ | ប្រធាន |
| - លោក JUNICHI SASAKI | សមាជិកក្រុមប្រឹក្សាភិបាល | សមាជិក |
| - លោក អ៊ុំ ពិសិដ្ឋ | នាយកប្រតិបត្តិ | កោះអញ្ជើញ |
| - លោក ព្រាប គណ្ឌឹង | នាយករងប្រតិបត្តិ | កោះអញ្ជើញ |
| - បុគ្គលិកទទួលបន្ទុក | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | សមាជិក/លេខាធិការ |

- ភារកិច្ច និងការទទួលខុសត្រូវ

- ពិនិត្យ និងអនុម័តទៅលើលក្ខខណ្ឌនៃកម្មវិធីសវនកម្មផ្ទៃក្នុង និងផែនការប្រចាំឆ្នាំ រួមទាំងគោលបំណង វិសាលភាព និងតារាងកាលវិភាគ
- ពិនិត្យមើលបញ្ហាទាំងឡាយណា ដែលអាចជះឥទ្ធិពលដល់ឯករាជ្យភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យ និងអនុម័តគោលការណ៍ និងនីតិវិធី
- ពិនិត្យមើលការរកឃើញ និងការតាមដានរបស់សវនករផ្ទៃក្នុង រួមទាំងចំណុចសំខាន់ៗ ដែលមិនយល់ស្របគ្នា រវាងគណៈគ្រប់គ្រង និងសវនករផ្ទៃក្នុងពាក់ព័ន្ធនឹងការត្រួតពិនិត្យ
- ធានាថាការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងបើកចំហរមានការចូលរួមក្នុងចំណោមគណៈកម្មាធិការសវនកម្ម សវនករឯករាជ្យ និងសវនកម្មខាងក្នុង
- ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម អាចចូលជួបសវនករផ្ទៃក្នុង និងប្រធានផ្នែក/នាយក នាយដ្ឋានសវនកម្មផ្ទៃក្នុងដោយមិនមានការចូលរួមពីគណៈគ្រប់គ្រង
- ប្រាប់ពីការរំពឹងទុករបស់គណៈកម្មាធិការសវនកម្ម ទៅកាន់សវនករផ្ទៃក្នុងឱ្យបានដឹងជាលាយលក្ខណ៍អក្សរ
- ទទួល និងពិនិត្យមើលរបាយការណ៍របស់សវនករផ្ទៃក្នុង ពាក់ព័ន្ធនឹងគុណភាព និងភាពទាន់ពេលវេលាកំណត់
- ពិនិត្យដាមតានការអនុវត្តតាមអនុសាសន៍លើការរកឃើញរបស់សវនករផ្ទៃក្នុង
- តាមដាន និងពិនិត្យឡើងវិញនូវគុណភាពនៃការផ្តល់សេវាកម្មសវនកម្មផ្ទៃក្នុង
- វាយតម្លៃដំណើរការរបស់ក្រុមហ៊ុនដែលមាន ដើម្បីតាមដាន និងវាយតម្លៃប្រសិទ្ធភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យមើលការរៀបចំផែនការសកម្មភាពរបស់សវនកម្មផ្ទៃក្នុង សវកម្មឯករាជ្យ និងការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម។

# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរសាច់ប្រាក់


ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

. ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

. ទំហំឥណទានរហូតដល់ : ២០០.០០០ ដុល្លារ

. រយៈពេលរហូតដល់ : ១០ ឆ្នាំ



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមភ្ជាប់នូវរបាយការណ៍នេះ ជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ **ហ្វូតាបា** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## ព័ត៌មានអំពីក្រុមហ៊ុន

**ហ្វូតាបា** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានធ្វើប្រតិបត្តិការអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម (“MOC”) ក្រោមលេខចុះបញ្ជី No.០០០១៦៩០៤ KH/២០១៥ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ផ្តោតសំខាន់ក្នុងការធ្វើសកម្មភាពអាជីវកម្មមីក្រូហិរញ្ញវត្ថុ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅ #៧៩៥ ផ្លូវព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## ក្រុមហ៊ុនមេ

ក្រុមហ៊ុនមេគឺក្រុមហ៊ុន Azuma & Co., Ltd ដែលជាក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសជប៉ុន ។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងកិច្ចការរបស់ក្រុមហ៊ុនដល់កាលបរិច្ឆេទនេះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ពុំមានការស្នើសុំបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងអំឡុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

| | |
|---|---|
| លោក ច្រឹក ផល្លី | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក យូសូកេ សាសាគី | អភិបាល |
| លោក ជូនីជី សាសាគី | អភិបាល |
| លោក ម៉ូតូ ហាម៉ាដា | អភិបាលឯករាជ្យ |
| លោក ង៉ែត សុវណ្ណារ៉ូ | អភិបាលឯករាជ្យ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្មដោយ Kreston Cambodia ប្រតិបត្តិការអាជីវកម្មក្រោមឈ្មោះក្រុមហ៊ុន ខេម អ៊ីខោនធីង & ថាកសឺវីស ឯ.ក (Cam Accounting & Tax Service Co., Ltd.)។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងបានបង្ហាញពីទិដ្ឋភាពពិតនិងត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់នេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលក៏តម្រូវឱ្យ៖

ក) អនុវត្តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព។

ខ) អនុលោមតាមតម្រូវការលាតត្រដាងរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ហើយប្រសិនជាមានការប្រាសចាកណាមួយពីស្តង់ដារ ទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់យោបល់លើចំនុចមិនត្រឹមត្រូវ

ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) ថែរក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែករណីមិនសមស្របណាកើតឡើង តែយើងសន្មតថាក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត និង។

ង) គ្រប់គ្រងផ្ទៃក្នុង និងរាល់ការសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ដូច្នេះត្រូវប្រាកដថាសេចក្តីសម្រេចទាំងនោះត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌខាងលើក្នុងការៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានគិតគូរពីបញ្ហាដូចខាងក្រោម៖

ក) ការផ្ទេរជាសារវន្តទាំងអស់ទៅ ឬពីទុនបម្រុង ឬសំវិធានធន ក្នុងអំឡុងពេលឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ខ) សំវិធានធនលើឱនភាពតម្លៃគណនីត្រូវទទួលនិងទ្រព្យសកម្មរយៈពេលខ្លីនិងវែងត្រូវធ្វើឡើងតាមការតម្រូវ។

គ) បំណុលទារមិនបានដែលទទួលស្គាល់ត្រូវកាត់ចេញ ប្រសិនបើមាន។

ឃ) វិធីសាស្ត្រដែលមានស្រាប់ក្នុងការវាយតម្លៃទ្រព្យសកម្ម ឬបំណុល គឺមិនអាចបំភាន់ ឬមិនសមរម្យទេ។

ង) មិនមានកាលៈទេសៈណាដែលត្រូវបានគេដឹងថា ចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនាំឱ្យមានការយល់ច្រឡំនោះទេ។

ច) ក្រុមប្រឹក្សាភិបាលបានបញ្ជាក់ថា គ្មានប្រតិបត្តិការ ឬព្រឹត្តិការណ៍ជាសារវ័ន្ត និងមិនធម្មតាកើតមានឡើងនៅក្នុងចន្លោះពេលកាលរិយបរិច្ឆេទបញ្ចប់របាយការណ៍ហិរញ្ញវត្ថុ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ អាចប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះឡើយ។

(ឆ) ក្រុមប្រឹក្សាភិបាលបានបញ្ជាក់ថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ គឺមិនរងផលប៉ះពាល់ជាសារវ័ន្តដោយប្រការណាមួយប្រតិបត្តិការ ឬព្រឹត្តិការណ៍ជាសារវ័ន្ត និងមិនធម្មតាទេ។

(ជ) គ្មានបំណុលផ្សេងៗជាយថាហេតុរបស់ក្រុមហ៊ុន ដែលអាចបង្ខំឱ្យអនុវត្តន៍ ឬទំនងជាអាចអនុវត្តន៍បានក្នុង រយៈពេលដប់ពីរខែបន្ទាប់ពីចុងការិយបរិច្ឆេទបញ្ចប់នៃឆ្នាំហិរញ្ញវត្ថុ អាចធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ច របស់ខ្លួន នៅពេលបំណុលដល់កាលកំណត់ឡើយ ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងនាមក្រុមប្រឹក្សាភិបាលនៃ**ហ្វូតាបា** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ខ្ញុំសូមបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយត្រូវបានបង្ហាញពីទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

តំណាងក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.
KINGDOM OF CAMBODIA

លោក ច្រឹក ផល្លី

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២៤

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

## មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ("ក្រុមហ៊ុន"(ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងរបាយការណ៍ចំណេញ ខាត និងចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ដូចមានបង្ហាញក្នុងទំព័រលេខ ៨ ដល់លេខ ៤៣។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) រួមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ("NBC")។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្នុងរបាយការណ៍នេះ។ យើងជឿថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មមួយផ្សេងទៀតដែលរបាយការណ៍ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ បានបង្ហាញមតិពិតប្រាកដ និង ត្រឹមត្រូវ។

## ឯករាជ្យភាព និងទំនួលខុសត្រូវសីលធម៌ផ្សេងៗ

យើងមានភាពឯករាជ្យពីក្រុមហ៊ុន ដោយអនុលោមតាមតម្រូវការសីលធម៌ដែលពាក់ព័ន្ធទៅនឹងសវនកម្មនៃ របាយការណ៍ហិរញ្ញវត្ថុរបស់យើងនៅក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញនូវទំនួលខុសត្រូវប្រកបដោយក្រមសីលធម៌ផ្សេង ទៀតរបស់យើងស្របតាមតម្រូវការទាំងនេះ។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករ

អភិបាលរបស់ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវរាល់ព័ត៌មានដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ ព័ត៌មាននោះ រួមបញ្ចូលទាំងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបញ្ចេញមតិលើរបាយការណ៍នេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ទំនួលខុសត្រូវរបស់សវនករ គឺគ្រាន់តែអានពីរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងពិចារណាថាតើ របាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនស៊ីសង្វាក់គ្នាខ្លាំងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ការយល់ដឹងរបស់យើងដែលទទួលបានក្នុងអំឡុងពេលធ្វើសវនកម្ម ទំនងជាបង្ហាញពីកំហុសជាសារវន្ត។

ប្រសិនបើយោងទៅតាមការងារដែលពួកយើងបានបំពេញ រួចសន្និដ្ឋានថា របាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានកំហុសជាសារវន្តដែលតម្រូវអោយយើងរាយការណ៍ពីការពិតនេះ។ យើងគ្មានអ្វីដែលត្រូវរាយការណ៍ពីបញ្ហានេះឡើយ។

## ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ

អភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ អភិបាលរបស់ក្រុមហ៊ុនទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអភិបាលក្រុមហ៊ុនយល់ថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជា សារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អភិបាលមានទំនួលខុសត្រូវលើការវាយតម្លៃ និរន្តរភាពរបស់ក្រុមហ៊ុនលាតត្រដាង

រាល់បញ្ហាដែលមានជាប់ពាក់ព័ន្ធជាមួយនឹងនិរន្តភាពរបស់ក្រុមហ៊ុននិងការប្រើប្រាស់មូលដ្ឋាននិរន្តរភាព លើកលែងតែអភិបាលមានបំណងចង់បិទក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសពិតប្រាកដក្រៅពីធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងគឺ ដើម្បីទទួលបាននូវការធានាសមហេតុផលអំពីរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល មិនមានកំហុសឆ្គងជាសារវន្ត មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំ និងការចេញរបាយការណ៍សវនករដែលរាប់បញ្ចូល ទាំងទស្សនៈរបស់យើង។ ការធានាសមហេតុផលគឺជាកម្រិតខ្ពស់នៃការធានា ប៉ុន្តែមិនធានាថាសវនកម្មដែលធ្វើឡើងស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា នឹងរកឃើញកំហុសជាសារវន្តនៅពេលកើតឡើងនោះទេ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសហើយត្រូវបានគេចាត់ទុកថាជាសារវន្ត ក្នុងមួយឬច្រើនករណីបូកបញ្ចូលគ្នា ដែលករណីទាំងនេះអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដែលផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈនិងរក្សានូវជំនាញវិជ្ជាជីវៈក្នុងការធ្វើសវនកម្មទាំងមូល។ យើងក៏:

(ក) កំណត់និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនថាដោយសារការក្លែងបន្លំឬកំហុស រៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបានភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់នឹងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ទស្សនៈរបស់យើង។ ហានិភ័យដែលមិនរកឃើញកំហុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងកំហុសដែលបណ្តាលមកពីភាពកំហុស ការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ ការលុបចោលដោយចេតនា ការលាតត្រដាងមិនពិត ឬការរំលោភប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។

(ខ) ទទួលបានការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសវនកម្មដើម្បីរៀបចំនីតិវិធី សវនកម្មដែលសមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

(គ) វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលបានប្រើនិងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។

(ឃ) សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់របស់អភិបាលើមូលដ្ឋាននិរន្តរភាពនៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានថា តើភាពមិនច្បាស់លាស់ជាសារវន្តមានទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាស់លាស់ជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់សវនកររបស់យើង ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុ ឬបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងផ្អែកលើភស្តុតាងសវនកម្ម ដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពអាជីវកម្ម។

(ង) វាយតម្លៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាងថាតើរបាយការណ៍ហិរញ្ញវត្ថុ មានប្រតិបត្តិការនិងព្រឹត្តិការណ៍ទាំងនោះបង្ហាញដោយត្រឹមត្រូវឬទេ។

យើងបានផ្តល់ព័ត៌មានជូនក្រុមអភិបាល ស្តីពីបញ្ហាផ្សេងៗ វិសាលភាពនិងពេលវេលាដែលបានគ្រោង ទុកសម្រាប់ធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលសវនកម្មរបស់យើង។

**តំណាងឱ្យក្រុមហ៊ុន ខេម អ៊ីខោនធីង & ថាក់សឺវីស**

ស្នងការគណនេយ្យ និងសវនកម្ម

**គាត ហេង CPA, ACCA**

**នាយកសវនកម្ម**

រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២៤

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣<br>ដុល្លារអាមេរិក | ២០២៣<br>ពាន់រៀល | ២០២២<br>ដុល្លារអាមេរិក | ២០២២<br>ពាន់រៀល |
|---|---|---|---|---|
| ទ្រព្យសកម្ម | | | | |
| សាច់ប្រាក់ក្នុងដៃ | ១៨.៤៦៦ | ៧៥.៤៣៤ | ៨៨.២៣៤ | ៣៦៣.២៥៩ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា | ៣៦០.១៤០ | ១.៤៧១.១៧២ | ៣៥៥.៧៤៧ | ១.៤៦៤.៦១០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ | ៤៦៦.៥៨៧ | ១.៩០៦.០០៨ | ១.៧២៦.៥៧៦ | ៧.១០៨.៣១៣ |
| ឥណទានផ្តល់ដល់អតិថិជន | ១៤.៣៨៣.០៧៦ | ៥៨.៧៥៤.៨៦៥ | ១៣.២៩៥.៩២០ | ៥៤.៧៣៩.៣០៣ |
| ទ្រព្យសកម្មផ្សេងៗ | ១៧៣.៣៩៦ | ៧០៨.៣២៣ | ១៧៨.៩២២ | ៧៣៦.៦២២ |
| ទ្រព្យ និងគ្រឿងបរិក្ខារ | ១៧៨.៣៧២ | ៧២៨.៦៥០ | ៩៨.៣៨១ | ៤០៥.០៣៥ |
| ទ្រព្យសកម្មអរូបី | ៨២៥ | ៣.៣៧០ | - | - |
| **ទ្រព្យសកម្មសរុប** | **១៥.៥៨០.៨៦២** | **៦៣.៦៤៧.៨២២** | **១៥,៧៤៣,៧៨០** | **៦៤.៨១៧.១៤២** |
| | | | | |
| បំណុល និងមូលធន | | | | |
| បំណុល | | | | |
| ប្រាក់កម្ចីពីសម្ព័ន្ធញាតិ | ៦.០៣៧.១៨២ | ២៤.៦៦១.៨៨៨ | ៦.៥៣៧.១៨២ | ២៦.៩១៣.៥៧៨ |
| ពន្ធពន្យារជាទ្រព្យជាបំណុល | ២៦០.៨០៣ | ១.០៦៥.៣៨០ | ១២៧.១៤៤ | ៥២៣.៤៥២ |
| បំណុលពន្ធលើប្រាក់ចំណូល | - | - | ៩១៤ | ៣.៧៦៣ |
| បំណុលផ្សេងៗ | ៦២.០៣១ | ២៥៣.៣៩៧ | ១១៨.១៥៨ | ៤៨៦.៤៥៦ |
| **បំណុលសរុប** | **៦.៣៦០.០១៦** | **២៥.៩៨០.៦៦៥** | **៦.៧៨៣.៣៩៨** | **២៧.៩២៧.២៤៩** |
| | | | | |
| មូលធន | | | | |
| ដើមទុន | ៧.០០០.០០០ | ២៨.០០០.០០០ | ៧.០០០.០០០ | ២៨.០០០.០០០ |
| ទុនបម្រុងបទប្បញ្ញត្តិ | ៨២៤.៤១៣ | ៣.៣៦៣.៣៦៩ | ៧៩៨.៧៤៩ | ៣.២៥៧.៨៨៨ |
| ប្រាក់ចំណេញរក្សាទុក | ១.៣៩៦.៤៣៣ | ៥.៦៨៩.៣៣៥ | ១.១៦១.៦៣៣ | ៤.៧២៤.៣០៨ |
| លំអៀងពីអត្រាប្តូរប្រាក់ | - | ៦១៤.៤៥៣ | - | ៩០៧.៦៩៧ |
| **មូលធនសរុប** | ៩.២២០.៨៤៦ | ៣៧.៦៦៧.១៥៧ | ៨.៩៦០.៣៨២ | ៣៦.៨៨៩.៨៩៣ |
| **បំណុល និងមូលធនសរុប** | **១៥.៥៨០.៨៦២** | **៦៣.៦៤៧.៨២២** | **១៥,៧៤៣,៧៨០** | **៦៤.៨១៧.១៤២** |

# របាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១.៨៨១.៧៤៩ | ៧.៧៣៣.៩៨៨ | ១.៨៨១.៤៤៧ | ៧.៦៨៩.៤៧៤ |
| ចំណាយការប្រាក់ | (៩៤.៥០៧) | (៣៨៨.៤២៤) | (៩៨.០៥៨) | (៤០០.៧៦៣) |
| ចំណូលការប្រាក់សុទ្ធ | ១.៧៨៧.២៤២ | ៧.៣៤៥.៥៦៤ | ១.៧៨៣.៣៨៩ | ៧.២៨៨.៧១១ |
| | | | | |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ៩៦.៧៨៧ | ៣៩៧.៧៩៥ | ១៧០.៦៤២ | ៦៩៧.៤១៤ |
| | | | | |
| ចំណាយបុគ្គលិក | (៨៥៤.០៣១) | (៣.៥១០.០៦៧) | (៧៧៤.០៩២) | (៣.១៦៣.៧១៤) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | (៥១១.២៥៣) | (២.១០១.២៥០) | (៥៣៣.៥៩៧) | (២.១៨០.៨១១) |
| សំវិធានធនលើឥណទានខាតបង់ | (១០៩.៣២២) | (៤៤៩.៣១៣) | (៥៧.៩៩៩) | (២៣៧.០៤២) |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៤០៩.៤២៣ | ១.៦៨២.៧២៩ | ៥៨៨.៣៤៣ | ២.៤០៤.៥៥៨ |
| | | | | |
| ពន្ធលើប្រាក់ចំណូល | (១៤៨.៩៥៩) | (៦១២.២២១) | (១៣៨.៩១៧) | (៥៦៧.៧៥៤) |
| ប្រាក់ចំណេញក្នុងឆ្នាំ | ២៦០.៤៦៤ | ១.០៧០.៥០៨ | ៤៤៩.៤២៦ | ១.៨៣៦.៨០៤ |
| | | | | |
| ប្រាក់ចំណេញពេញលេញផ្សេងៗ | - | - | - | - |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | - | (២៩៣.២៤៤) | - | ៣៧៩.៤៥៤ |
| សរុបប្រាក់ចំណេញពេញលេញក្នុងឆ្នាំ | ២៦០.៤៦៤ | ៧៧៧.២៦៤ | ៤៤៩.៤២៦ | ២.២១៦.២៥៨ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | មូលធន<br>ដុល្លារអាមេរិក | ទុនបម្រុងបទប្បញ្ញត្តិ<br>ដុល្លារអាមេរិក | ចំណេញបង្គរ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| សមតុល្យថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២ | ៧.000,000 | ៤៧៤.២៥២ | ១.0៣៦.៧0៤ | ៨.៥១0.៩៥៦ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ៤៤៩.៤២៦ | ៤៤៩.៤២៦ |
| ការផ្ទេរ | - | ៣២៤.៤៩៧ | (៣២៤.៤៩៧) | - |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៧.000.000 | ៧៩៨.៧៤៩ | ១.១៦១.៦៣៣ | ៨.៩៦0.៣៨២ |
| | | | | |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ២៦0.៤៦៤ | ២៦0.៤៦៤ |
| ការផ្ទេរ | - | ៨២៤.៤១៣ | (៨២៤.៤១៣) | - |
| និយ័តកម្ម | - | (៧៩៨.៧៤៩) | ៧៩៨.៧៤៩ | - |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៧.000.000 | ៨២៤.៤១៣ | ១.៣៩៦.៤៣៣ | ៩.២២0.៨៤៦ |

| | មូលធន<br>ខ្មែរពាន់រៀល | ទុនបម្រុងបទប្បញ្ញត្តិ<br>ខ្មែរពាន់រៀល | ចំណេញបង្គរ<br>ខ្មែរពាន់រៀល | លំអៀងអត្រាប្តូរប្រាក់<br>ខ្មែរពាន់រៀល | សរុប<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| សមតុល្យថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២ | ២៨.000.000 | ១.៩៣១.៦៦៨ | ៤.២១៣.៧២៤ | ៥២៨.២៤៣ | ៣៤.៦៧៣.៦៣៥ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ១.៨៣៦.៨0៤ | - | ១.៨៣៦.៨0៤ |
| ការផ្ទេរ | - | ១.៣២៦.២២0 | (១.៣២៦.២២0) | - | - |
| លំអៀងពីអត្រាប្តូរប្រាក់ | - | - | - | ៣៧៩.៤៥៤ | ៣៧៩.៤៥៤ |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ២៨.000.000 | ៣.២៥៧.៨៨៨ | ៤.៧២៤.៣0៨ | ៩0៧.៦៩៧ | ៣៦.៨៨៩.៨៩៣ |
| | | | | | |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ១.0៧0.៥0៨ | - | ១.0៧0.៥0៨ |
| ការផ្ទេរ | - | ៣.៣៨៨.៣៣៩ | (៣.៣៨៨.៣៣៩) | - | - |
| និយ័តកម្ម | - | (៣.២៨២.៨៥៨) | ៣.២៨២.៨៥៨ | - | - |
| លំអៀងពីអត្រាប្តូរប្រាក់ | - | - | - | (២៩៣.២៤៤) | (២៩៣.២៤៤) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ២៨.000.000 | ៣.៣៦៣.៣៦៩ | ៥.៦៨៩.៣៣៥ | ៦១៤.៤៥៣ | ៣៧.៦៦៧.១៥៧ |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិ | | | | |
| ចំណេញមុនបង់ពន្ធ | ៤០៩.៤២៣ | ១.៦៨២.៧២៩ | ៥៨៨.៣៤៣ | ២.៤០៤.៥៥៨ |
| និយ័តកម្មសម្រាប់: | | | | |
| រំលស់ | ៦៣.០៦៩ | ២៥៩.២១៤ | ២៥.៨៥៥ | ១០៥.៦៦៩ |
| ចំណេញពីការលក់ទ្រព្យ និងគ្រឿងបរិក្ខារ | (១.០០៩) | (៤.១៤៧) | - | - |
| សំវិធានធនលើឥណទានខាតបង់ | ១០៩.៣២៣ | ៤៤៩.៣១៨ | ៥៧.៩៩៩ | ២៣៧.០៤២ |
| លុបចោលទ្រព្យ និងគ្រឿងបរិក្ខារ | - | - | ៥.៧៦២ | ២៣.៥៤៩ |
| ប្រតិបត្តិការចំណេញមុនបម្រែបម្រួលទុនបង្វិល | ៥៨០.៨០៦ | ២.៣៨៧.១១៤ | ៦៧៧.៩៥៩ | ២.៧៧០.៨១៨ |
| បម្រែបម្រួល: | | | | |
| ប្រាក់កម្ចី និងបុរេប្រទាន | (១.១៩៦.៧២១) | (៤.៩១៨.៥២៣) | ៣៣.៧១៦ | ១៣៧.៧៩៧ |
| ទ្រព្យសកម្មផ្សេងៗ | ៥.៥២៦ | ២២.៧១២ | (៦.៥១១) | (២៦.៦១០) |
| បំណុលផ្សេងៗ | (៥៦.១២៧) | (២៣០.៦៨២) | (១៨២.៥២២) | (៧៤៥.៩៦៧) |
| លំហូរសាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (៦៦៦.៥១៦) | (២.៧៣៩.៣៧៩) | ៥២២.៦៤២ | ២.១៣៦.០៣៨ |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (១៦.២១៤) | (៦៦.៦៤១) | (៩១.១៩៥) | (៣៧២.៧១៤) |
| លំហូរសាច់ប្រាក់សុទ្ធដែលប្រើក្នុងសកម្មភាពប្រតិបត្តិការ | (៦៨២.៧៣០) | (២.៨០៦.០២០) | ៤៣១.៤៤៧ | ១.៧៦៣.៣២៤ |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | | | | |
| ទឹកប្រាក់ពីការលក់ទ្រព្យ និងគ្រឿងបរិក្ខារ | ១.០០៩ | ៤.១៤៧ | - | - |
| ទឹកប្រាក់ទិញទ្រព្យ និងគ្រឿងបរិក្ខារ | (១៤៣.០៦០) | (៥៨៧.៩៧៧) | (៤៥.៩៣៤) | (១៨៧.៧៣២) |
| ទឹកប្រាក់ទិញទ្រព្យសកម្មអរូបី | (៨២៥) | (៣.៣៩១) | - | - |
| លំហូរសាច់ប្រាក់សុទ្ធដែលប្រើក្នុងសកម្មភាពវិនិយោគ | (១៤២.៨៧៦) | (៥៨៧.២២១) | (៤៥.៩៣៤) | (១៨៧.៧៣២) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | | | | |
| ការសងបំណុល | (៥០០.០០០) | (២.០៥៥.០០០) | ៩៨.០៥៨ | ៤០០.៧៦៣ |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន | (៥០០.០០០) | (២.០៥៥.០០០) | ៩៨.០៥៨ | ៤០០.៧៦៣ |
| | | | | |
| ការផ្លាស់ប្តូរសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | (១.៣២៥.៦០៦) | (៥.៤៤៨.២៤១) | ៤៨៣.៥៧១ | ១.៩៧៦.៣៥៥ |
| | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី០១ ខែមករា | ១.៨២០.៨៨៩ | ៧.៤៩៦.៥៩៩ | ១.៣៣៧.៣១៨ | ៥.៤៤៨.២៣៤ |
| លម្អៀងពីបង្គរការប្រែសម្រួលរូបិយប័ណ្ណ | - | (២៥.១២៦) | - | ៧២.០១០ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី៣១ ខែធ្នូ | ៤៩៥.២៨៣ | ២.០២៣.២៣២ | ១.៨២០.៨៨៩ | ៧.៤៩៦.៥៩៩ |
| | | | | |
| ការផ្ទៀងផ្ទាត់នូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | | | |
| | | | | |
| សាច់ប្រាក់ក្នុងដៃ | ១៨.៤៦៦ | ៧៥.៤៣៤ | ៨៨.២៣៤ | ៣៦៣.២៥៩ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា | ១០.១៤០ | ៤១.៤២២ | ៥.៧៤៧ | ២៣.៦៦០ |
| (មិនរាប់បញ្ចូលប្រាក់តម្កល់តាមបទប្បញ្ញត្តិ) | | | | |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ | ៤៦៦.៦៧៧ | ១.៩០៦.៣៧៦ | ១.៧២៦.៩០៨ | ៧.១០៩.៦៨០ |
| | ៤៩៥.២៨៣ | ២.០២៣.២៣២ | ១.៨២០.៨៨៩ | ៧.៤៩៦.៥៩៩ |


MORTGAGE
APPLICATION FORM
Housing Register number:
Name(s):
Applicant 1:
APPROVED
Telephone Home:
Work:
Mobile:
Email:
Members of household to be housed:
Name:
Relationship:
Date of Birth:
An owner occupier:
A tenant of a housing association:
A tenant of housing provided with job:
Living with friends/family/lodger:
In HM Forces quarters:
A shared owner lessee:
A private tenant:

# ដៃគូសហប្រតិបត្តិការណ៍

## ដៃគូ

FORTE INSURANCE

CBC

ប.ស.ស NSSF National Social Security Fund

Cambodia Microfinance Association

Wing

truemoney

## ម្ចាស់កម្ចី

AZUMA & CO., LTD.

## រាល់ មតិរិះគន់ ឬ បណ្តឹងតវ៉ា ផ្សេងៗ
## សូមទំនាក់ទំនងមកកាន់លេខ

០៧០ ២២៩ ៣៣៣

០១៧ ២៣៧ ៨៨៥



០៧០ ៣១២ ៣៣៣

ស្កេនត្រង់នេះដើម្បីទទួលបានព័ត៌មានលម្អិត